ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- រីករាយឆ្នាំថ្មី!
- វត្តខ្នារករកោះ ស្រុកបូរីជលសារ ខេត្តតាកែវ
- កម្មសិក្សាទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៧៧ ខែមករា ឆ្នាំ២០២៣

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៧៧ ខែមករា ឆ្នាំ២០២៣

## មាតិកា


### សំបុត្រ

◆ រីករាយឆ្នាំថ្មី! .................................១

### ផ្នែកឯកសារ

◆ សុក រុន៖ កម្មកររទេះភ្លើងត្រែងត្រយឹង.... ៤

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ដួង សឿន៖ កងវរសេនាតូចសំណាប ................ ៧
◆ ប្តីរបស់ខ្ញុំត្រូវខ្មែរក្រហមឃោសនាបោក .... ៩
◆ ខ្ញុំមានជីវិតរស់ ដោយសារមេឃុំជាប់រវល់... ១១
◆ ខ្ញុំហៀបនឹងស្លាប់ដោយសារតែជាប់ខ្សែ.. ១៣
◆ ទិត្យ ណៃស្រ៊ុង៖ កងចល័តស្រុកកំពង់.... ១៥
◆ ធុន ស្រ៊ាង៖ កងចល័តនៅស្រុកកំពង់សៀម... ១៧
◆ មី រីន៖ អ្នកមើលកុមារនៅក្នុងរបបខ្មែរ ... ១៩
◆ វត្តខ្នារកកោះ ស្រុកបូរីជលសារ ខេត្ត..... ២១
◆ ខ្មែរក្រហមចាប់កូនរបស់ខ្ញុំយកទៅសម្លាប់ ...២៣
◆ ខ្មែរក្រហមបាញ់សម្លាប់ប្តីខ្ញុំ................២៥

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ កម្មសិក្សាទៅកាន់មជ្ឈមណ្ឌលសន្តិភាព.. ២៧
◆ កម្មសិក្សាថ្នាក់មូលដ្ឋាននៅមជ្ឈមណ្ឌល ឯកសារ ខេត្តកំពង់ចាម ..................... ៣១
◆ គណៈប្រតិភូខេត្តត្បូងឃ្មុំធ្វើទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីពី ........... ៣៦
◆ ទស្សនកិច្ចសិក្សាទៅកាន់មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ ................................ ៤២
◆ ចំណាប់អារម្មណ៍របស់អ្នកស្ម័គ្រចិត្តកម្ពុជាខេត្ត តាកែវ ពេលចុះកម្មសិក្សានៅ ............៤៤
◆ ប្រជាជន មន្ត្រីមូលដ្ឋានឃុំ និងសិស្សានុសិស្ស មកទស្សនាពព័រណ៍រូបថតអចិន្ត្រៃយ៍ ..... ៤៦




សិស្សមកពីវិទ្យាល័យ ស្វាយរមៀត ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា» រៀបចំដោយមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


◆ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមរៀបចំ វេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី........ ៤៩
◆ វេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ ..................... ៥៤

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ ក្រាំ ម៉ែយ៖ ខ្ញុំបាត់បង់កូនពីរនាក់នៅ ......៥៨
◆ ទួលពិឃាដ ................................. ៦១



**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ៖** ឆាំង យុ, ដារ៉ារដ្ឋ មេត្តា, ភួង សុខថា, ទី ស្រីផា, ទូច វណ្ណេត, ជន ម៉ារី, ដេង ពង្សរ៉ាស៊ី, ហេង ឡៃហៀន, ឈុំ រ៉ា, ថុន ស្រីពេជ្រ, ភា រស្មី, វី ស៊ីថា, ង៉ាន់ វីន, ជីម សុខគា និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ផាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ីភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង ពៅង


Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# រីករាយឆ្នាំថ្មី!

**ឆាំង យុ**



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាថតរូបជុំគ្នានៅថ្ងៃរៀបការរបស់ ដារ៉ារដ្ឋ មេត្តា នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ នៅឃុំព្រែកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ (ឆាំង យុ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រីករាយឆ្នាំថ្មី! ឆ្លៀតនៅក្នុងគ្រាដើមដំបូងនៃឆ្នាំ២០២៣នេះ បុគ្គលិករបស់ខ្ញុំនិងរូបខ្ញុំបាទផ្ញើរ លំសូមប្រសិទ្ធិពរឆ្នាំថ្មី បវរប្រសើរជូនចំពោះឯកអគ្គរដ្ឋទូតនិងសហការី។ យើងខ្ញុំសង្ឃឹមថា ឯកអគ្គរដ្ឋទូតបានចំណាយពេលវេលាវិស្សមកាលកន្លងទៅដោយក្តីរីករាយ និងសុខសុវត្ថិភាព។

ឆ្នាំ២០២២ គឺជាឆ្នាំប្រកបដោយការរីកលូតលាស់និងឱកាសដ៏វិសេសវិសាលសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំបាទចង់ចែករំលែកនូវការបូកសរុបការងារក្នុងឆ្នាំមុន និងបច្ចុប្បន្នភាពនៃគម្រោងរបស់យើងសម្រាប់ឆ្នាំ២០២៣។ ទីស្នាក់ការកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលពីមុនមានទីតាំងស្ថិតនៅក្បែរវិមានឯករាជ្យ រាជធានីភ្នំពេញ បានរើទីតាំងមកនៅក្បែរបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ទីតាំងថ្មីនេះ គឺស្របទៅនឹងចក្ខុវិស័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុង

ការបង្កើតជាមធ្យោបាយប្រកបដោយវិជ្ជាជីវៈ គាំពារដល់នវានុវត្តភាពនិងកិច្ចសហប្រតិបត្តិការ ខណៈដែលអាចធានាបានថាមានទីធ្លាគ្រប់គ្រាន់សម្រាប់ការសញ្ជឹងគិតនិងងាយស្រួលសម្រាប់សាធារណជនក្នុងការប្រើប្រាស់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានធ្វើបច្ចុប្បន្នភាពលើដំណើរការក្នុងការប្រើប្រាស់ឯកសារ និងបរិក្ខារ ទាំងអស់របស់ខ្លួនដែរ ដោយក្នុងនោះរួមមានមជ្ឈមណ្ឌលឯកសារនៅតាមបណ្តាខេត្ត ដើម្បីគាំពារដល់ការចូលទៅប្រើប្រាស់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានងាយស្រួលជាងមុន។ ទន្ទឹមនឹងនេះដែរ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការផ្តល់សេវាកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងបានអនុវត្តដំណើរការផ្តល់មតិយោបល់ស្ថាបនាជាសាធារណៈ ដោយសាធារណជនអាចផ្តល់មតិយោបល់យ៉ាងងាយស្រួល ហើយមតិយោបល់នោះនឹងត្រូវបានពិចារណាដោយថ្នាក់ដឹកនាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ជាចុងក្រោយ ក្នុងគោលបំណងទទួលស្គាល់អំពីសារសំខាន់នៃការប្រើប្រាស់ឯកសារនៅតាមបណ្តាទីដាច់ស្រយាលក្នុងផ្ទៃប្រទេស មជ្ឈមណ្ឌលឯកសារកម្ពុជា បានបន្តពង្រីក និងធ្វើឲ្យប្រសើរឡើងនូវធនធាននិងសមត្ថភាពរបស់សាខាមជ្ឈមណ្ឌលឯកសារនៅតាមបណ្តាខេត្ត ក៏ដូចជាការទាញយកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមប្រព័ន្ធអនឡាញមកប្រើប្រាស់។

ក្រុមការងាររបស់យើងបានរៀបចំបំពាក់មជ្ឈមណ្ឌលឯកសារ ទាំងប្រាំរួចរាល់សព្វគ្រប់ ក្នុងនោះរួមមាន៖ ១) មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅខេត្តឧត្តរមានជ័យ ២) មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខេត្តកំពង់ចាម ៣) មជ្ឈមណ្ឌលឯកសារកោះថ្ម នៅខេត្តត្បូងឃ្មុំ ៤) មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅខេត្តព្រៃវែង និង ៥) មជ្ឈមណ្ឌលឯកសារខេត្តតាកែវ នៅខេត្តតាកែវ។ គោលបំណងស្នូលនៃមជ្ឈមណ្ឌលឯកសារ ទាំងប្រាំនេះ គឺដើម្បីគាំពារដល់ការប្រើប្រាស់ឯកសារប្រវត្តិសាស្ត្រក្នុងបណ្តុំឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅតាមបណ្តាតំបន់ដាច់ស្រយាល និងបង្កើនការយល់ដឹងជាសាធារណៈអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារ ទាំងអស់សម្រេចគោលដៅដែលកំណត់ទុក តាមរយៈការរៀបចំជាបន្ទប់អំណាននៅក្នុងមជ្ឈមណ្ឌលនីមួយៗ ក៏ដូចជាសកម្មភាពនៅក្នុងមូលដ្ឋាន ដោយមានបុគ្គលិកនិងទៅជួបសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រមទាំងចែកចាយឯកសារ និងព័ត៌មានទៅកាន់ទីតាំងដាច់ស្រយាលនៅក្នុងតំបន់របស់ខ្លួន។ មជ្ឈមណ្ឌលឯកសារនីមួយៗ មានតម្កល់ទុកឯកសារជាក់លាក់ដែលមានសារប្រយោជន៍ពិសេសសម្រាប់សហគមន៍ក្នុងតំបន់របស់ខ្លួន ដែលចូលរួមចំណែកដល់ការផ្សារភ្ជាប់ខ្លួនរបស់មជ្ឈមណ្ឌលឯកសារនីមួយៗទៅនឹងប្រជាជនក្នុងតំបន់ៗ។ ជារៀងរាល់ខែ នាយកមជ្ឈមណ្ឌលឯកសារតាមបណ្តាខេត្តម្នាក់ៗ តែងចំណាយពេលចំនួន១០ថ្ងៃ នៅតាមភូមិស្រុក ដើម្បីជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, រៀបចំវេទិកាថ្នាក់រៀនជាមួយសិស្សានុសិស្ស និងទទួលស្វាគមន៍សាធារណជនមកកាន់មជ្ឈមណ្ឌលឯកសាររបស់ខ្លួន ដើម្បីស្រាវជ្រាវឯកសារនិងបរិក្ខារផ្សេងៗ។ ទន្ទឹមនឹងនេះដែរ យើងក៏មានក្រុមការងារនៅប្រចាំការតាមបណ្តាមជ្ឈមណ្ឌល ដើម្បីសម្របសម្រួលដល់ភ្ញៀវនិងសំណើសុំឯកសារផ្សេងៗ។ បន្ថែមពីនេះ ខណៈដែលយើងបានជ្រើសរើសអ្នកស្ម័គ្រចិត្តកម្ពុជានៅតាមបណ្តាមជ្ឈមណ្ឌលឯកសារទាំងអស់ យើងនៅតែបន្តស្វាគមន៍អ្នកហាត់ការមកពីបរទេស។

គិតគូរគ្រោងទុកសម្រាប់ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា មានសេចក្តីសោមនស្សចំពោះកម្មវិធីស្ម័គ្រចិត្តសម្រាប់យុវជន ដែលផ្តល់ជាឱកាសដ៏វិសេសវិសាលក្នុងការបង្កើនសមត្ថភាព និងជំរុញសកម្មភាពនៅតាមមូលដ្ឋានឲ្យប្រព្រឹត្តទៅដោយឋិតថេរចីរកាល។ កម្មវិធីស្ម័គ្រចិត្តសម្រាប់យុវជនដែលរួមបញ្ចូលយុវជនក្លៀវក្លាចំនួនប្រមាណជាង៥០០នាក់ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ត្រូវបានស្គាល់ថាជា កម្មវិធីអ្នកស្ម័គ្រចិត្តកម្ពុជា។ កម្មវិធីអ្នកស្ម័គ្រចិត្តកម្ពុជា ផ្តល់ឲ្យយុវជននូវជំនាញជាអ្នកដឹកនាំដ៏សំខាន់ៗ គួបផ្សំជាមួយ នឹងឱកាសក្នុងការតបស្នងទៅកាន់សហគមន៍ ព្រមទាំងផ្សារភ្ជាប់ទៅនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារកម្ពុជា ចាត់ទុកកម្មវិធីនេះថាជា សមាសធាតុចំបាច់ចំពោះសកម្មភាពនៅតាមមូលដ្ឋានសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនិងសមាជិកគ្រួសាររបស់គាត់ ដែលរស់នៅក្នុងទីជនបទដាច់ស្រយាល។ កម្មវិធីនេះ ប្រព្រឹត្តទៅដោយចំណាយធនធានតិច ហើយគឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីដែលប្រកបដោយប្រជាប្រិយភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពីព្រោះថា កម្មវិធីនេះបានបង្កើតជាឱកាសសម្រាប់ការសន្ទនា និងការសិក្សារៀនសូត្រអន្តរជំនាន់ ព្រមទាំងលើកកម្ពស់សិទ្ធិក្នុងសហគមន៍។

ខ្ញុំបាទសូមគោរពអញ្ជើញឯកអគ្គរដ្ឋទូត ធ្វើទស្សនកិច្ចដ៏វិការមកកាន់ទីស្នាក់ការកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, បណ្ណាល័យសម្តេចម៉ែ និងសាខាមជ្ឈមណ្ឌលឯកសារនៅតាមបណ្តាខេត្ត នៅពេលវេលាសមស្របណាមួយ។ ខ្ញុំបាទទន្ទឹងរង់ចាំស្វាគមន៍ឯកអគ្គរដ្ឋទូតនិងសហការីគ្រប់ពេលវេលា។



ទេសភាពបឹងស្នេហ៍ស្ថិតនៅឃុំព្រៃកណ្តៀង ក្នុងស្រុកពាមរក៍ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សុក រុន ៖ កម្មកររទេះភ្លើងត្រែងត្រយឹង

ដារ៉ារដ្ឋ មេត្តា



អ្នកលក់នៅតាមស្ថានីយ៍រថភ្លើង បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩។
(ដេវីដ ហក/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សុក រុន អាយុ៨២ឆ្នាំ នៅក្នុងឆ្នាំ១៩៧៨។ ខ្ញុំរៀបការរួចហើយ។ ខ្ញុំមានស្រុកកំណើតនៅភូមិអន្លង់បារាំង ឃុំរការកោះ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ តាំងពីតូចខ្ញុំរស់នៅជាមួយឪពុកម្តាយដោយប្រកបមុខរបរធ្វើស្រែ។ នៅពេលខ្ញុំមានអាយុ១៣ឆ្នាំឪពុកធំខ្ញុំឈ្មោះ សុក អតីតសង្ឃរាជវត្តបន្ទាយរការយកខ្ញុំទៅនៅជាមួយ។ ខ្ញុំរស់នៅជាមួយឪពុកធំបានរយៈពេល១ឆ្នាំ ឪពុកធំក៏បានឲ្យខ្ញុំបួសនៅវត្តបន្ទាយរការ។ បន្ទាប់ពីខ្ញុំបួសបានរយៈពេល១ឆ្នាំខ្ញុំក៏សឹកវិញ។

នៅក្នុងឆ្នាំ១៩៥៧ ខ្ញុំចូលធ្វើជាគិញឲ្យចៅហ្វាយស្រុកគិរីរម្យឈ្មោះ ស្នួន តាមរយៈឪពុកធំ គឺជាអ្នកអប់រំខ្ញុំ។ ភារកិច្ចរបស់ខ្ញុំគឺស៊ើបរកខ្មែរក្រហម, អប់រំប្រជាជនឲ្យស្អប់ខ្មែរក្រហម និងកសាងកម្លាំងគិញបន្ថែម។ ក្រោយមក តាមការចាត់តាំងរបស់ចៅហ្វាយស្រុកគិរីរម្យ និងឪពុកធំ ខ្ញុំបានទៅទាក់ទងជាមួយឈ្មោះ ឆាត់ គឺជាប៉ូលិស នៅគិរីរម្យ, ឈ្មោះ ឆុំ គឺជាសង្ឃរាជវត្តចំបក់, ម៉ន, មួង និង នី គឺជាហ្មដីរី នៅក្រាំងដីវ៉ាយ, អុន គឺជាកម្មករកាប់ឈើ, ឈួន គឺជាចៅកែធ្យូង នៅកំពង់ស្ពឺ, យឹង កម្មករ

កាប់ឈើ, ណាវ មេឃុំក្រាំងដីវ៉ាយ, សឿន មេឃុំតាំងសំរោង និង មូល សង្ឃរាជវត្តអន្លង់ជុំ។

នៅក្នុងឆ្នាំ១៩៦៤ ឪពុកធំ ខ្ញុំចាត់តាំងខ្ញុំឲ្យបួសវិញដើម្បីងាយស្រួលក្នុងការស៊ើបរកខ្មែរក្រហម។ នៅចុងឆ្នាំនេះដដែល ឪពុកធំខ្ញុំ, សួន, ធាត់, ឆុំ និងគល់បានអប់រំខ្ញុំបញ្ចូលជា សេ.អ៊ី.អា។ ក្នុងរយៈពេលនោះខ្ញុំទាក់ទងជាមួយខ្សែចាស់របស់ខ្ញុំមានម៉ន, នី, មួង, ណាវ, អុន, សឿន និង យឹង។ តាមរយៈឪពុកធំខ្ញុំ ខ្ញុំទាក់ទងជាមួយខ្សែថ្មីទៀតមានជួប, អ៊ិន, ឈុំ, ឈួន, ប៉ាន់, សួស គឺជាកម្មករចៅកែ ជួន និងឈ្មោះហេង គឺជាអ្នកលក់គ្រឿងទេសនៅភូមិបន្ទាយរការ។ យើងធ្វើសកម្មភាពមិនឲ្យប្រជាជនរត់ចូលព្រៃ ដោយលើកឡើងអំពីខ្មែរក្រហមកាចសាហាវ កាប់សម្លាប់ប្រជាជនស្លូតត្រង់។ នៅក្នុងឆ្នាំ១៩៦៥ ខ្ញុំបានសឹកពីបួសរួចហើយទៅនៅជាមួយឪពុកធំ។

នៅឆ្នាំ១៩៦៦ឪពុកធំខ្ញុំចាត់តាំងឲ្យទៅបង្កប់ខ្លួននៅកន្លែង ឡធ្យូង ស្ថិតនៅក្រុងកំពង់ស្ពឺដើម្បីកសាងកម្លាំង និងស៊ើបរកមើលខ្មែរក្រហម។

នៅឆ្នាំ១៩៦៨ ឪពុកធំរៀបចំឲ្យខ្ញុំមានគូស្រករជាមួយប្រពន្ធឈ្មោះ ឈុំ ភី។ ក្រោយពីខ្ញុំរៀបការរួច ខ្ញុំអប់រំប្រពន្ធខ្ញុំឲ្យធ្វើជា សេ.អ៊ី.អា ដែរ ហើយខ្ញុំមសារអប់រំលើកឡើងថា អង្គការ សេ.អ៊ី.អា មានចិត្តល្អ ចេះជួយឧបត្ថម្ភអ្នកខ្វះខាតឲ្យតែសុខចិត្តចូលជាគិញ។ ក្រោយពីការអប់រំហើយ ប្រពន្ធខ្ញុំដើរអប់រំ ឃោសនាប្រជាជនកុំឲ្យស្រឡាញ់ខ្មែរក្រហម។

នៅឆ្នាំ១៩៧០ ខ្ញុំធ្វើសកម្មភាពចាប់បានខ្មែរក្រហមចំនួន៣នាក់នៅពេជអន្ទង ឈ្មោះជួប, អ៊ិន និង ថោង។ ក្រោយមក ខ្ញុំបានយកអ្នកទាំងនោះទៅសួរចម្លើយពីកន្លែងលាក់មីមគ្លួច ហើយខ្មែរក្រហមទាំងបីនាក់ប្រាប់ទីតាំងលាក់មីមគ្លួចនៅភ្នំកំពូលបី។ ខ្ញុំបាននាំគ្នាទៅដើររកកន្លែងលាក់មីមគ្លួចនៅកំពូលភ្នំ និងបានឃើញមីមគ្លួចពិតមែន។ មីមគ្លួចនោះមានចំនួនប្រហែលជា៥ជាលធំៗ ហើយខ្ញុំក៏នាំជីរីដើរជាន់កម្ទេច និងយកមកវិញកន្ទះបាវដើម្បីរាយការណ៍ឲ្យឈ្មោះ សួន។

នៅខែវិច្ឆិកា ឆ្នាំ១៩៧១ ភូមិរបស់ខ្ញុំត្រូវបានរំដោះ។ នៅអំឡុងពេលនោះ ខ្ញុំនៅទាក់ទងជាមួយខ្សែចាស់ ឪពុកធំខ្ញុំឈ្មោះ ណាវ, ឆុំ, មួង, ម៉ន, នី, យឹង, ហេង និងរួមគ្នាធ្វើសកម្មភាពបំផ្លាញដំណាំប្រជាជនដោយកាប់ដើមចេក ដកដំឡូងមី ចោលទាំងអស់។

នៅឆ្នាំ១៩៧២ អង្គការចាប់ខ្ញុំ, ឪពុកធំខ្ញុំ, សុខ, ណាវ, នី, មួង, ម៉នយកទៅមន្ទីរឃុំឃាំង នៅជិតវត្តក្រសាំងដុះឡើងដើម្បីសួរចម្លើយ។ រហូតមកដល់ខែមករា ឆ្នាំ១៩៧៣ ទើបអង្គការចាត់តាំងខ្ញុំ, ឪពុកធំខ្ញុំ ឲ្យទៅវាយដែកនៅភូមិថ្មហោង ឃុំតាសាល ស្រុក២៧ តំបន់៣២។ អង្គការបានដាក់ខ្នោះជើងខ្ញុំនៅពេលធ្វើការ។ នៅខែកក្កដា ឆ្នាំ១៩៧៣ អង្គការផ្លាស់ខ្ញុំឲ្យទៅវាយដែក នៅទំនប់ទឹកព្រែកត្នោត។ ខ្ញុំស្នាក់នៅទីនោះអស់រយៈពេល៥ខែ។

នៅខែមករា ឆ្នាំ១៩៧៤ អង្គការដកខ្ញុំឲ្យមកដំដែកធ្វើកាំបិតនៅអូរតាវៀក នៅជិតភូមិដក់ពរ។ នៅពេលនោះ ខ្ញុំនៅទាក់ទងជាមួយឈ្មោះឪពុកធំខ្ញុំ ហើយបានរួមគ្នាធ្វើសកម្មភាពដោយធ្វើឲ្យកាំបិតថយចុះគុណភាព និងលត់ឲ្យរឹងហួសកម្រិតដើម្បីឲ្យស្រួយ ដើម្បីកាប់ឆាប់បាក់ ឬធ្វើឲ្យទន់ប្រើការមិនកើត។ នៅខែមីនា ឆ្នាំ១៩៧៤ អង្គការដកខ្ញុំនិងឪពុកធំមកធ្វើរទេះនៅវត្តបន្ទាយរការ នៅពេលនោះ អង្គការបានដោះលែងខ្ញុំដោយមិនមានដាក់ខ្នោះជើងទៀតទេ។ ក្រោយមកអង្គការចាត់តាំងឲ្យខ្ញុំកាប់ដីដាំដំឡូង។ ពេលនោះ ខ្ញុំបានជាប់ទាក់ទងជាមួយខ្សែចាស់វិញ មានឈ្មោះ ជួប, យឹង, អុន, អ៊ិន និង ឈុំ។ ខ្ញុំបានឲ្យឪពុកធំខ្ញុំទាក់ទងខ្សែចាស់ឡើងវិញដែរ និងបានលើកផែនការបំផ្លាញបដិវត្តន៍ចាប់តាំងពី គោ ក្របី រទេះ រនាស់ នង្គ័ល ព្រមទាំងផលដំណាំប្រជាជនធ្វើយ៉ាងណាកុំឲ្យបដិវត្តន៍រីកចម្រើនទៅមុខ។

នៅខែមិថុនា ឆ្នាំ១៩៧៥ ក្រោយរំដោះអង្គការដកខ្ញុំមកនៅអូរតាចន ដើម្បីពង្រាបដីសង់រោងអារឈើធ្វើកំណល់ផ្លូវរទេះភ្លើង។ ពេលនោះខ្ញុំបានទាក់ទងជាមួយឈ្មោះ ឆាត់ គឺជាអតីតមេឃុំតាំង

បង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ នៅក្នុងខែតុលា ឆ្នាំ១៩៧៥ អង្គការចាត់តាំងខ្ញុំ, អុន, យឹង, ហេង ទៅធ្វើស្ពានសម្រាប់ ឡានឆ្លងអូរតាចន។ ខ្ញុំ, អុន និង យឹង បានធ្វើសកម្មភាពធ្វើស្ពានឲ្យបុះគុណភាពដោយគ ឈើភ្ជាប់គ្នាដាក់មុខខ្ទីដើម្បីឲ្យឆាប់បាក់ ហើយឈើវែងខ្ញុំកាត់ខ្លីៗទើបតភ្ជាប់គ្នាវិញ។

នៅខែមេសា ឆ្នាំ១៩៧៦ អង្គការដកខ្ញុំពីអូរតាចន ឲ្យទៅធ្វើរោងអារកំណាល់ផ្លូវរទេះភ្លើងនៅត្រែងត្រយឹង។ ពេលនោះខ្ញុំជាប់ទាក់ទង ជាមួយឈ្មោះ ឆាត់ ដដែល។ ក្រោយមកតាមការចាត់តាំងពីឈ្មោះ ឆាត់ ខ្ញុំទាក់ទងជាមួយឈ្មោះ ឌឿន, សារឿន, សីហា និងបានធ្វើសកម្មភាពនៅពេលអង្គការចាត់តាំងឲ្យចាក់ស៊ីម៉ង់ត៍ធ្វើជើងម៉ាស៊ីន។ នៅខែមិថុនា ឆ្នាំ១៩៧៦ តាគល់ គឺជាអនុប្រធានរោងអាឈើត្រែងត្រយឹងបានចាត់តាំងខ្ញុំ, ឌឿន និង សារឿន ទៅយកម៉ូទ័រ ពីដោះកញ្ញរ យកមកដាក់ម៉ាស៊ីនឆាបរណា។ ពេលនោះ ឌឿ, សារឿនបានឆ្លៀតឱកាសនាំខ្ញុំឲ្យស្គាល់ឈ្មោះ អួច យាមឃ្លាំងសម្ភារ នៅដោះកញ្ញរ, ថាន់ ធ្វើស្ពានផ្លូវរទេះភ្លើង នៅអូរក្រាំងអំបិល ដោយលើកអំពីផែនការកម្ទេចឃ្លាំងសម្ភារនៅដោះកញ្ញរ និងកំណត់ពេលដុតនៅពេលណាដែលមានព្រៃឆេះនៅជិតៗនោះ។ នៅខែសីហា ឆ្នាំ១៩៧៦ ពេលខ្ញុំធ្វើម៉ាស៊ីនរួចហើយ អង្គការក៏ដកខ្ញុំមកនៅជួយកាប់ព្រៃធ្វើស្រែនៅបន្ទាយដោះកញ្ញរវិញ។ នៅខែកញ្ញា ឆ្នាំ១៩៧៦ អង្គការដកខ្ញុំមកនៅ អូរបម្ពងផ្អក និងបានចាត់តាំងខ្ញុំឲ្យយកពុម្ពមកចាក់ធ្វើលូទឹក។ នៅពេលនោះខ្ញុំបានទាក់ទងជាមួយខ្សែចាស់របស់ខ្ញុំ ដោយបានរួមគ្នាធ្វើសកម្មភាពលាយស៊ីម៉ង់ត៍តិច និងដាក់ខ្សាច់ច្រើនដើម្បីឲ្យខូចគុណភាព ហើយនៅពេលទឹកហូរប្រោះនឹងឆាប់បាក់។

នៅខែសីហាឆ្នាំ១៩៧៧ ឌឿន, សារឿនបានហៅខ្ញុំ, ចក់, ភិន និង ម៉ន ទៅដាក់ផែនការដុតបំផ្លាញស្រូវនៅដីអំបិល។ ផែនការនេះមិនបានសម្រេចព្រោះអង្គការចាប់ឈ្មោះ ឌឿន, សារឿនមុន។ នៅខែកញ្ញា ឆ្នាំ១៩៧៧ អង្គការចាប់ខ្ញុំតែម្តង។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ00៤២៦។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ សុក រុន ពិតប៉ុណ្ណានោះទេ?**



សកម្មភាពលក់ដូរនិងអ្នកដំណើរនៅតាមស្ថានីយ៍រថភ្លើង បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩។ (ដេវីដ ហក/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផុង សឿនៈ កងរែកសំណាប

**ភួង សុខថា**



ផុង សឿន និង ប្រពន្ធរបស់គាត់ នៅភូមិពន្លៃ ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។
( ដេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

ខ្ញុំឈ្មោះ ផុង សឿន ភេទប្រុស អាយុ៧៨ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិពន្លៃ ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំគឺជាកូនកសិករនិងមានបងប្អូនចំនួន៥នាក់។ ខ្ញុំគឺជាកូនទី៣នៅក្នុងចំណោមបងប្អូនរបស់ខ្ញុំ។ នៅអាយុ១៣ឆ្នាំ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាពន្លៃ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៤ ខ្ញុំ ក៏ឈប់រៀនដោយសារ កើតមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់ សម្តេច ព្រះនរោត្តម សីហនុ និងកើតមានចលាចលនៅក្នុងស្រុកភូមិ។ ចាប់តាំងពីពេលនោះមក សង្គ្រាមរវាងរដ្ឋការ លន់ នល់ និងក្រុមខ្មែររំដោះ (ខ្មែរក្រហម) ក៏ចាប់ផ្តើមផ្ទុះឡើងជាបន្តបន្ទាប់។ នៅអំឡុងពេលនោះ ផ្ទះសម្បែង ផលដំណាំ មាន់ ទា ជ្រូក គោ ក្របី របស់ប្រជាជននៅក្នុងភូមិត្រូវឆេះ បាក់បែក និងងាប់អស់ជាច្រើនក្បាល។ មកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានយកឈ្នះទៅលើរបប លន់ នល់ ទាំងស្រុង ចំណែក លន់ នល់ បានភៀសខ្លួនទៅរស់នៅសហរដ្ឋអាមេរិក។ ចាប់តាំងពីថ្ងៃនោះមក ខ្មែរក្រហមចាប់ផ្តើមកាន់អំណាច និងគ្រប់គ្រងប្រជាជនទាំងអស់នៅក្នុងប្រទេស។ បន្ទាប់មក ខ្មែរក្រហមបានដាក់ផែនការឲ្យប្រជាជនធ្វើការហួសកម្លាំង និងមិនឲ្យហូបចុកគ្រប់គ្រាន់ឡើយ។ ចំណែកខ្ញុំត្រូវប្រធានសហករណ៍

ប្រើឲ្យទៅរែកសំណាបឲ្យប្រជាជនស្ទូង ក្នុងមួយថ្ងៃឲ្យបានចំនួន២០០កណ្តាប់។ ប៉ុន្តែខ្ញុំត្រូវដើរប្រមាណ ២គីឡូពីកន្លែងសំណាប ទៅដល់កន្លែងស្ទូង។

មួយរយៈក្រោយមក មេកងខ្មែរក្រហមឈ្មោះ ដេត រៀបចំផ្លាស់ខ្ញុំចេញពីស្រុកមេសាង ឲ្យទៅឈើកាច់បាភ្នំដើម្បីជីកព្រែកនៅ ទីនោះ ប៉ុន្តែខ្ញុំសុំអនុញ្ញាតពីកម្មាភិបាលខ្មែរក្រហមនៅធ្វើការនៅក្នុងស្រុកមេសាងដដែល ពីព្រោះឪពុករបស់ខ្ញុំកំពុងឈឺ ចំណែកបងស្រីពីនាក់ទៀតរបស់ខ្ញុំបានស្លាប់ជាបន្តបន្ទាប់ដោយសារជំងឺ។ កម្មាភិបាលខ្មែរក្រហមបានយល់ព្រមតាមសំណើររបស់ខ្ញុំ និងបានចាត់តាំងអ្នកផ្សេងដែលនៅក្នុងក្រុមជាមួយខ្ញុំឲ្យទៅជីកព្រែកនៅឈើកាច់បាភ្នំជំនួសខ្ញុំវិញ ហើយមួយឆ្នាំក្រោយមក គាត់ក៏បានវិលត្រឡប់មកវិញ ហើយមកធ្វើការងារជាមួយក្រុមរបស់ខ្ញុំនៅស្រុកមេសាងដដែល។

នៅដើមឆ្នាំ១៩៧៩ ខ្មែរក្រហមបានជម្លៀសប្រជាជននៅក្នុងភូមិឃុំ រួមទាំងគ្រួសាររបស់ខ្ញុំឲ្យទៅកាន់ភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ខ្ញុំនិងគ្រួសារបានដើរមកដល់ឈើកាច់បាភ្នំ ក៏នាំគ្នាត្រឡប់មកភូមិកំណើតវិញ ព្រោះខ្ញុំដឹងថាកងទ័ពរណសិរ្សសាគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមករំដោះប្រជាជនកម្ពុជាហើយ។ ពេលមកផ្ទះ ខ្ញុំនិងក្រុមគ្រួសារ ព្រមទាំងប្រជាជននៅក្នុងភូមិបាននាំគ្នាទៅប្រមូលយកស្រូវយកមកទុក និងចែកគ្នាហូប។ រឿងរ៉ាវទាំងនេះខ្ញុំនៅតែចងចាំរហូតមកដល់សព្វថ្ងៃ។



វាលស្រែនៅរដូវប្រាំង នៅក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។
( ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ប្ដីរបស់ខ្ញុំត្រូវខ្មែរក្រហមឃោសនាបោកបញ្ឆោតយកទៅសម្លាប់

ធី ស្រីផា



គូច ហាង អាយុ៨៤ឆ្នាំ សព្វថ្ងៃរស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គូច ហាង អាយុ៨៤ឆ្នាំ មានស្រុកកំណើតរស់នៅភូមិថ្មី ស្រុកថ្មគោល ខេត្តបាត់ដំបង។ បច្ចុប្បន្នខ្ញុំរស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមឡើងកាន់អំណាចធ្វើឲ្យប្រជាជនមានភាពជ្រួលច្របល់។ ពេលនោះខ្មែរក្រហមប្រកាសស្វែងរកអ្នកធ្លាប់ធ្វើជាទាហាន លន់ នល់ ដើម្បីទៅច្បាំងជាមួយខ្មាំងនៅតាមព្រំដែនដោយទទួលបានប្រាក់ខែច្រើន ប្រសិនបើទាហានណាព្រមមកចុះឈ្មោះ។ ប្ដីរបស់ខ្ញុំពេលនោះគឺជាទាហាន លន់ នល់ និងក្រុមរបស់គាត់ប្រមាណជិត១០នាក់ផ្សេងទៀត បានស្ម័គ្រចិត្តទៅតាមយោធាខ្មែរក្រហម។ ខ្ញុំជំទាស់មិនឲ្យទៅជាមួយខ្មែរក្រហម ប៉ុន្តែគាត់មិនស្ដាប់ខ្ញុំ។ គាត់ប្រាប់ខ្ញុំឲ្យនាំកូនស្រីចាកចេញជាមួយបងប្រុសរបស់ខ្ញុំនៅពេលបងប្រុសខ្ញុំមកដល់។ ដោយសារតែស្ថានភាពច្របូកច្របល់ពេក ប្ដីរបស់ខ្ញុំបានចាកចេញទៅ។

ក្រុមគ្រួសាររបស់ខ្ញុំបានមករស់នៅឃុំនិមិត្ត ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ រហូតដល់ឆ្នាំ១៩៧៦ ទើបខ្មែរក្រហមជម្លៀសគ្រួសាររបស់ខ្ញុំបន្តទៅនៅភូមិថ្មី ស្រុកថ្មគោល ខេត្តបាត់ដំបង។ ចំណែកកូនស្រីរបស់ខ្ញុំចាប់ផ្ដើមឈឺគ្រុនក្ដៅខ្លួនខ្លាំង ហើយរយៈពេលបីថ្ងៃបន្ទាប់មកក៏ស្លាប់ទៅ។ ទោះបីយ៉ាងណាខ្ញុំនៅតែទន្ទឹងរង់ចាំដំណឹងពីប្ដីរបស់ខ្ញុំ។ រហូតដល់ថ្ងៃមួយ ខ្ញុំបានជួបពូម្នាក់គឺជាទាហាន លន់ នល់ ដែលចេញទៅជាមួយប្ដីរបស់ខ្ញុំ។ គាត់បានរៀបរាប់ប្រាប់ខ្ញុំថា នៅថ្ងៃដែលគាត់ទៅជាមួយប្ដីរបស់ខ្ញុំ កូនស្រីរបស់គាត់ដួលសន្លប់ ហើយគាត់ក៏ត្រឡប់ក្រោយមកមើលកូនស្រីវិញ។ បន្ទាប់មកគាត់ព្យាយាមរត់តាមឡានដឹកទាហានប៉ុន្តែ ឡានចាកចេញទៅចោលគាត់។ គាត់អង្គុយរង់ចាំឡានផ្សេងទៀតមកដឹកទាហាន លន់ នល់ ដែលចុះចូលជាមួយខ្មែរក្រហម ប៉ុន្តែដោយសារចិត្តមិនដាច់ទៅចោលប្រពន្ធកូន ពេលឡានដឹកទាហានរបស់ខ្មែរក្រហមមកដល់ គាត់ក៏សម្រេចចិត្តមិនឡើងជិះឡាន ហើយដើរត្រឡប់មករកប្រពន្ធកូនវិញ។ ដូច្នេះហើយទើបគាត់នៅមានជីវិតរស់។ គ្មាននណា

ម្នាក់ដឹងថា ទាហាន លន់ នល់ ដែលដឹកទាំងឡាននោះ ត្រូវយោធាខ្មែរក្រហមនាំទៅទីណាទេ ព្រោះបាត់ដំណឹងរហូត។

នៅឆ្នាំ១៩៧៧ ប្អូនប្រុសរបស់ខ្ញុំអាយុ២០ឆ្នាំ បានធ្លាក់ខ្លួនឈឺ ព្រោះធ្វើការងារលើសកម្លាំង និងមិនមានអាហារហូបគ្រប់គ្រាន់ ហើយបានស្លាប់ទៀត។ ខ្ញុំបានស្នើសុំអង្គការផ្លាស់មករស់នៅឃុំឈ្នួរ ស្រុកកំណើតខាងម្ដាយរបស់ខ្ញុំវិញ ប៉ុន្តែកម្មាភិបាលខ្មែរក្រហមសួរខ្ញុំថា មិត្តឯងចង់ទៅណាមិនពេញចិត្តចំពោះការចាត់តាំងរបស់អង្គការមែនទេ? ពុដូច្នេះខ្ញុំមិនហ៊ានសុំទៀតទេ ទើបទ្រាំរស់នៅទីនោះរហូតដល់ឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមចូលមក ទើបខ្ញុំត្រឡប់មករស់នៅស្រុកកំណើតជាមួយម្ដាយវិញ។ ខ្ញុំនៅសល់កូនស្រីរបស់ខ្ញុំពីរនាក់ទៀតដែលនៅរស់ជាមួយម្ដាយរបស់ខ្ញុំ នៅឯស្រុកកំណើត។ ខ្ញុំបានរស់នៅជាមួយកូន និងម្ដាយរហូតមកដល់សព្វថ្ងៃ។



តូច ហាង និងទី ស្រីផា អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៤ នៅខេត្តបន្ទាយមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្ញុំមានជីវិតរស់ ដោយសារមេឃុំជាប់រវល់

ធី ស្រីផា



ថាប់ ឆាយ អាយុ៨៦ឆ្នាំ បច្ចុប្បន្នរស់នៅភូមិសំរោងធំ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ថាប់ ឆាយ អាយុ៨៦ឆ្នាំ បច្ចុប្បន្នរស់នៅភូមិសំរោងធំ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវអង្គការចាត់ឲ្យចូលក្នុងក្រុមកងចល័តដើរប្រូតស្រូវនៅតាមវាលស្រែ។ ជារៀងរាល់ថ្ងៃខ្ញុំធ្វើការងារយ៉ាងលំបាកនៅក្រោមកម្ដៅថ្ងៃក្ដៅហែង និងមិនមានម្លប់ដើម្បីជ្រក។ ខ្ញុំធ្វើការរហូតវិលមុខនិងហូរទឹកភ្នែក ប៉ុន្តែមិនហ៊ានឈប់សម្រាកឡើយ។ ថ្ងៃមួយ ពេលខ្ញុំកំពុងបោកស្រូវស្រាប់តែស្រូវប៉ើងចូលភ្នែកធ្វើឲ្យខ្ញុំឈឺផ្សារគ្រាប់ភ្នែកជាខ្លាំង។ ខ្ញុំញីភ្នែកជាញឹកញាប់រហូតដល់ពិការភ្នែកទាំងសងខាងរហូតមកដល់សព្វថ្ងៃ។

នៅក្នុងរបបខ្មែរក្រហម កងឈ្លបតែងតែតាមដានខ្ញុំគ្រប់ពេល ព្រោះសង្ស័យថាខ្ញុំគឺជាអតីតទាហានស៊ើបការណ៍របស់ លន់ នល់។ មានថ្ងៃមួយពេលខ្ញុំកំពុងធ្វើការងារ ស្រាប់តែយោធាខ្មែរក្រហមពីរនាក់បានមកហៅខ្ញុំទៅប្រជុំជាមួយមេឃុំឈ្មោះ ខាត់។ ខាត់ គឺជាអ្នកសម្លាប់មនុស្សដ៏សាហាវម្នាក់ ហើយអ្នកដែលមេឃុំនេះហៅទៅជួបគឺមិនដែលមានជីវិតវិលត្រឡប់មកវិញទេ។ ខ្ញុំធ្វើដំណើរចេញទៅជាមួយយោធាខ្មែរក្រហមទាំងពីរនាក់ ដោយមិនបានលាប្រពន្ធឡើយ ព្រោះប្រពន្ធខ្ញុំជាប់រវល់ទៅប្រូតស្រូវនៅតាមកងចល័ត។ ពេលធ្វើដំណើរតាមផ្លូវ ខ្ញុំបានជួបកូនប្រុសរបស់ខ្ញុំ ដែលស្កាត់រត់មករកខ្ញុំបន្ទាប់ពីទទួលដំណឹងថា ខ្ញុំត្រូវអង្គការហៅទៅប្រជុំនៅឃុំឈ្នួរ។ ខ្ញុំបានផ្ដែផ្ដាំកូនប្រុសរបស់ខ្ញុំថា «ពុកទៅប្រជុំហើយ ប្រសិនបើហួសរយៈពេលបីថ្ងៃមិនឃើញពុកវិលត្រឡប់មកវិញទេ នោះមានន័យថា ពុកស្លាប់ហើយកុំរង់ចាំផ្លូវពុកអី ប្រាប់ម៉ែឯងផង»។ ពេលនោះស្រាប់តែយោធាខ្មែរក្រហមស្រែកថា «ឆាប់ទៅ! រវល់តែផ្ដែផ្ដាំអីទៅប្រជុំសោះ ធ្វើមើលតែទៅងាប់ចឹង»។ កូនប្រុសរបស់ខ្ញុំហូរទឹកភ្នែករលីងរលោង។ ខ្ញុំក៏ធ្វើដំណើរទៅមុខបណ្ដើរងាកក្រោយមើលកូនបណ្ដើររហូតដល់ផុតកន្ទុយភ្នែក ព្រោះគ្មានសង្ឃឹមថា

នឹងមានជីវិតបានវិលត្រឡប់មកជួបប្រពន្ធកូនវិញទេ។

លុះទៅដល់ឃុំឈ្នួរប្រហែលម៉ោង៥ល្ងាច យោធាខ្មែរក្រហមបានឲ្យខ្ញុំអង្គុយរង់ចាំមេឃុំ ខាត់ ដែលជាប់រវល់និងមិននៅកន្លែង។ ខ្ញុំអង្គុយរង់ចាំគាត់អស់រយៈពេលពីរបីម៉ោងរហូតដល់យប់ នៅតែមិនឃើញគាត់មក។ ពេលនោះកងឈ្លបបានហៅខ្ញុំហូបដំឡូងដែលដុតក្នុងភ្នក់ភ្លើងកុំឲ្យខ្ញុំឃ្លាន។ ខ្ញុំក៏តបទៅវិញថា «អត់ទេលោកកូន ឪហូបរួចហើយបានមក»។ ខ្ញុំហូបអ្វីមិនចូលទេ ព្រោះពេលនោះអារម្មណ៍របស់ខ្ញុំពោរពេញដោយភាពភ័យតក់ស្លុតនូវអ្វីដែលជិតនឹងកើតឡើងក្នុងពេលដ៏ខ្លីខាងមុខ។ ខ្ញុំអង្គុយរង់ចាំមេឃុំ ខាត់ រហូតដល់ម៉ោង៨យប់ ក៏មានយោធាខ្មែរក្រហមដើរមកប្រាប់ខ្ញុំថា « អ៊ំអើយ ទៅវិញសិនទៅ បង ខាត់ មិនមកទេ ឆាប់ទៅអ៊ំ! យប់ហើយ យកដំឡូងដុតនោះទៅផ្ញើកូនអ៊ំទៅ»។ បន្ទាប់ពីឮបែបនេះ ខ្ញុំភ័យផងអរផង។ ខ្ញុំក៏ធ្វើដំណើរត្រឡប់មកផ្ទះវិញទាំងយប់ងងឹត។ ពេលមកដល់ក្នុងផ្ទះ ខ្ញុំឃើញកូនរបស់ខ្ញុំកំពុងយំ។ កូនរបស់ខ្ញុំក៏និយាយមកកាន់ខ្ញុំថា «ខ្ញុំហៀបនឹងប្រាប់រឿងនេះទៅម៉ែហើយ ពុកមកដល់ល្មម»។



ថាប់ ឆាយ អាយុ៨៦ឆ្នាំ បច្ចុប្បន្នរស់នៅភូមិសំរោងធំ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្ញុំហៀបនឹងស្លាប់ដោយសារតែថាប់ ខ្សែស្រឡាយប្អូនធ្វើធាហាន លន់ នល់

ធី ស្រីផា



ថាប់ ភិត អាយុ៧៧ឆ្នាំ រស់នៅភូមិសំរោងធំ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ ធី ស្រីផា អ្នកស្ម័គ្រចិត្តជំនាន់ទី៤ នៅខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ថាប់ ភិត អាយុ៧៧ឆ្នាំ រស់នៅភូមិសំរោងធំ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ កាលពីកុមារភាព ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០សង្គមចាស់។ នៅពេលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា នៅឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមស្រាវជ្រាវប្រវត្តិបងប្អូនប្រជាជននៅក្នុងភូមិៗ ប្រជាជនមួយចំនួនដែលមិនដឹងពីការបោកបញ្ឆោតរបស់ខ្មែរក្រហម ក៏ឆ្លើយប្រាប់ត្រង់ថា ខ្លួនមានបងប្អូនក្រុមគ្រួសារជាអ្នកធ្វើការងារនៅក្នុងរបប លន់ នល់ ក៏ត្រូវខ្មែរក្រហមហៅទៅប្រជុំ ប្តូរជម្រៀសទៅតំបន់ផ្សេងហើយបាត់ខ្លួនរហូតមកដល់សព្វថ្ងៃ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវអង្គការចាត់ឲ្យទៅធ្វើការងារនៅកងចល័ត ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមស៊ើបដឹងថាប្អូនប្រុសរបស់ខ្ញុំឈ្មោះ ថាប់ សាវ៉ាន់ គឺជាទាហាន លន់ នល់។ បន្ទាប់មក ខ្មែរក្រហមបានហៅខ្ញុំប្រជុំចំនួនបីលើក៖

ប្រជុំលើកទី១) ក្រោយពេលប្អូនរបស់ខ្ញុំបាត់ខ្លួនមួយខែ ខ្មែរក្រហមហៅខ្ញុំទៅប្រជុំនិងសួរខ្ញុំថា ភិត ឯងនិង អេង ត្រូវជាបងប្រុស សាវ៉ាន់ មែនទេ? ពេលនោះខ្ញុំគិតថា ប្អូនប្រុស សាវ៉ាន់ បាត់ខ្លួនពីផ្ទះរាប់ខែប្រហែលជាបាត់បង់ជីវិតហើយ ទើបខ្ញុំឆ្លើយប្រាប់ខ្មែរក្រហមតាមត្រង់ថា សាវ៉ាន់ ធ្លាប់ធ្វើជាទាហានកាលពីមុនៗ បន្ទាប់ពីខ្ញុំឆ្លើយសំណួររួចខ្មែរក្រហមឲ្យខ្ញុំត្រឡប់មកផ្ទះវិញ។

ប្រជុំលើកទី២) នៅខែកក្កដា ឆ្នាំ១៩៧៨ ដដែល ខ្មែរក្រហមបានហៅបងប្អូនខ្ញុំបីនាក់រួមមាន ខ្ញុំ, អេង និង វ៉ែន ទៅប្រជុំនៅឃុំឈ្នួរមានជ័យ។ ខ្ញុំភិតភ័យយ៉ាងខ្លាំង រីឯ អេង ព្រួយបារម្ភពេកគិតអ្វីមិនចេញ អង្គុយជក់តែបារីស្លឹកសង្កែ។ ពេលនោះខ្មែរក្រហមនៅខាងលើផ្ទះកំពុងពិភាក្សាគ្នា ចំណែកខ្ញុំបីនាក់នៅខាងក្រោមផ្ទះ។ ពេលឃើញឡានយោធាខ្មែរក្រហម

បើកមកម្តងៗ ខ្ញុំតក់ស្លុតខ្លាំងណាស់ៗ បងប្អូនរបស់ខ្ញុំទាំង៣នាក់អង្គុយរង់ចាំរហូតដល់ម៉ោង៩យប់ ទើបប្រធានសហករណ៍ដែលនៅប្រជុំខាងលើផ្ទះឈ្មោះ រុន ស្រែកប្រាប់ថា «ពុកអេងអើយ ពុកអេង ពុកអេងឯងត្រឡប់ទៅផ្ទះសិនទៅ ប្រហែលគ្មានអ្នកណាមកប្រជុំទេ»ៗ អេង ក៏ឆ្លើយតបទៅវិញថាបាទៗ ពេលនោះយើងទាំងបីនាក់ភ័យផងអរផង ខ្លាចចាញ់ល្បិចកលខ្មែរក្រហម ក៏នាំគ្នាជិះកង់វិលត្រឡប់មកខ្ទមវិញទាំងស្ងន់ស្លោៗ លុះត្រឡប់មកដល់ផ្ទះយើងក៏ពិភាក្សាបបួលគ្នារត់ទៅប្រទេសថៃ ប៉ុន្តែយើងមិនបានទៅទេព្រោះមានប្រជាជនមួយចំនួនបានរត់ទៅមុនអស់ហើយៗ ក្រោយមក មានបុរសម្នាក់ឈ្មោះ គៀល ដែលរត់ទៅថៃ ប៉ុន្តែរត់ទៅមិនដល់ក៏ត្រឡប់ចូលមកក្នុងភូមិវិញក៏ត្រូវអង្គការហៅទៅប្រជុំ ចំណែក អេង ក៏អង្គការហៅទៅជាមួយបុរសម្នាក់នោះដែរៗ ចាប់តាំងពីថ្ងៃនោះមកបាត់ខ្លួន អេង រហូតៗ

ប្រជុំលើកទី៣) នៅថ្ងៃមួយក្នុងខែសីហា ឆ្នាំ១៩៧៨ ពេលខ្ញុំកំពុងភ្ជួរស្រែដូចសព្វដង ស្រាប់តែប្រធានសហករណ៍ឈ្មោះ រុន ដែលជាកម្មាភិបាលខ្មែរក្រហមមកពីភូមភាគនិរតីសួរខ្ញុំថា «បងឯងប្រាប់ខ្ញុំមើលនណារត់ទៅថៃខ្លះថ្ងៃមុន បើជួបប្តីងដំណឹងជួយប្រាប់ផង ហើយកុំឲ្យមកវិញៗ អ៊ំ ភិត ឯងកុំរត់ទៅណាឲ្យសោះ បើខ្ញុំនៅទីនេះអ៊ំមិនស្លាប់ទេ»ៗ ខ្ញុំក៏ឆ្លើយតបទៅវិញថា ខ្ញុំមិនបានដឹងថាអ្នកណារត់ទៅខ្លះទេៗ ខ្ញុំធ្វើការនៅក្នុងភូមិរហូតដល់កងទ័ពវៀតណាមចូលមក និងវាយផ្តួលរំលំរបបខ្មែរក្រហម ទើបខ្ញុំត្រឡប់មករស់នៅជួបជុំប្រពន្ធកូនវិញៗ


ចម្ការពោត នៅខេត្តបន្ទាយមានជ័យៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទិត្យ ណៃស្រ៊ុង៖ កងចល័តស្រុកកំពង់សៀម

ទូច វណ្ណាត



ទិត្យ ណៃស្រ៊ុង អាយុ៦៨ឆ្នាំ រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។
(លី ដេវីដ / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ទិត្យ ណៃស្រ៊ុង អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ អៀង និងមានកូនស្រីម្នាក់។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ឪពុករបស់ខ្ញុំឈ្មោះ ទិត្យ យាង និងម្តាយឈ្មោះ ភិន ហេង។ ខ្ញុំជាកូនទី៥ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៥នាក់។ ខ្ញុំកើតនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម នេះតែម្តង។

កាលនៅវ័យក្មេងខ្ញុំទៅរៀននៅសាលាបឋមសិក្សាកំពង់ក្របីដល់ថ្នាក់ទី៩ ពីសង្គមចាស់។ បន្ទាប់មកខ្ញុំបានឈប់រៀន មកជួយធ្វើការងារជាមួយឪពុកម្តាយ ដោយសារជីវភាពលំបាក។ មិនយូរប៉ុន្មានក៏មានរដ្ឋប្រហាររបស់ លន់ នល់ នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ទម្លាក់សម្តេចព្រះនរោត្តម សីហនុ ហើយពេលនោះអ្នកភូមិជាច្រើនបានចូលរួមបាតុកម្មដង្ហែទៅទីរួមខេត្តកំពង់ចាមដើម្បីប្រឆាំងរដ្ឋប្រហារ។ នៅចន្លោះឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ កងទ័ពរំដោះខ្មែរក្រហមចូលមកឃោសនានៅក្នុងភូមិ ដូច្នេះទាហាន លន់ នល់ ក៏បានបើកការវាយប្រហារ និងផ្លោងគ្រាប់បែកពីភ្នំប្រុស ព្រមទាំងទម្លាក់គ្រាប់បែកលើកងទ័ពរំដោះខ្មែរក្រហម។ នៅឆ្នាំ១៩៧៣ ក្រុមគ្រួសារខ្ញុំរត់ភៀសខ្លួនទៅរស់នៅភូមិកំពង់ក្របីមួយ

រយៈ។ នៅឆ្នាំ១៩៧៤ គ្រួសាររបស់ខ្ញុំបានវិលត្រឡប់មកភូមិកំណើតវិញ ហើយខ្មែរក្រហមក៏ចាប់ផ្តើមប្រមូលប្រជាជនឲ្យធ្វើការងារប្រវាស់ដៃដើម្បីជួយប្រូតស្រូវ និងប្រមូលផលដំណាំចែកគ្នាហូប។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមបង្កើតជាសហករណ៍ និងបែងចែកប្រជាជនធ្វើការងារនៅតាមកងចល័ត។ នៅពេលនោះខ្ញុំធ្វើការនៅកងចល័តស្រុក គឺរែកដី, លើកភ្លឺស្រែ និងលើកទំនប់នៅល្អាក។ ខ្ញុំត្រូវងើបពីម៉ោង៤ទៀបភ្លឺដើម្បីទៅប្រជុំជួររយៈពេលកន្លះម៉ោងតាមការចាត់ចែងរបស់ប្រធានកង ដើម្បីឲ្យខ្ញុំធ្វើការងារតាមផែនការដែលថ្នាក់លើដាក់ឲ្យ។ ខ្ញុំធ្វើការងារពីម៉ោង៦ដល់ម៉ោង១១ថ្ងៃត្រង់ ទើបឈប់សម្រាកហូបបបរ។ បន្ទាប់មកខ្ញុំបន្តធ្វើការងារពីម៉ោង១ដល់ម៉ោង៥ល្ងាចទើបសម្រាក។

នៅឆ្នាំ១៩៧៧ ខ្ញុំធ្វើការងារនៅកងចល័តរែកដីនិងលើកទំនប់ដដែល ប៉ុន្តែត្រូវផ្លាស់ទីតាំងពីកន្លែងមួយទៅកន្លែងមួយទៀត។ នៅចុងឆ្នាំ១៩៧៨ អង្គការបានរៀបការឲ្យកងចល័តចំនួន១៣គូ នៅក្នុងនោះក៏មានខ្ញុំម្នាក់ដែរ។ នៅឆ្នាំ១៩៧៩ ខ្ញុំបានបន្តធ្វើការនៅតាមការដ្ឋានរហូតដល់ពេលមានកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយចូលមកដល់រំដោះប្រជាជនចេញពីខ្មែរក្រហម ទើបខ្ញុំត្រឡប់មកភូមិកំណើតវិញ។



ផ្ទះរបស់ប្រជាជននៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្លូវលំនៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ធុន ស្រ៊ាង៖ កងចល័តនៅស្រុកកំពង់សៀម

**ទូច វណ្ណាត**



ធុន ស្រ៊ាង អាយុ៦៨ឆ្នាំ រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (លី ដេវីដ / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ធុន ស្រ៊ាង អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្ដីឈ្មោះ វណ្ណី និងមានកូនប្រុសចំនួន៣នាក់។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ឪពុកខ្ញុំឈ្មោះ ធុន និងម្ដាយឈ្មោះ ពេញ ឡូន។ ខ្ញុំគឺជាកូនទី៦ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន ៩ នាក់។ ខ្ញុំកើតនៅភូមិកោះរកាក្រៅ ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ កាលពីក្មេង ខ្ញុំរៀននៅសាលាបឋមសិក្សាកោះរកាដល់ថ្នាក់ទី៩ សង្គមចាស់។ ខ្ញុំបានឈប់រៀន មកជួយធ្វើការងារជាមួយឪពុកម្ដាយ ដោយសារជីវភាពលំបាក។

បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំឃើញមានបាតុកម្មផ្ទុះឡើង និងមានក្បួនបាតុករដង្ហែទៅ ទីរួមខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ មានការប្រយុទ្ធគ្នារវាង ទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមជាបណ្ដើរៗ។ បន្ទាប់មកខ្ញុំឆ្លងទន្លេទៅរស់នៅភូមិកំពង់រាបមួយរយៈ។ តមកក្រុមគ្រួសារខ្ញុំបានធ្វើដំណើរទៅរស់នៅភូមិល្វា បានរយៈពេលកន្លះឆ្នាំទៀត។

នៅឆ្នាំ១៩៧២ ខ្ញុំបានវិលត្រឡប់មករស់នៅភូមិកំណើតដែលគ្រប់គ្រងដោយកងទ័ពរំដោះខ្មែរក្រហមវិញ។ នៅឆ្នាំ១៩៧៣ ទីរួមខេត្តកំពង់ចាមត្រូវបានឡោមព័ទ្ធទៅដោយកងទ័ពរំដោះខ្មែរក្រហម គឺមានតែផ្លូវទឹកប៉ុណ្ណោះ ដែលកងទ័ព លន់ នល់ អាចចូលមកដល់ទីរួមខេត្ត។ នៅពេលទាហានម៉ារីន លន់នល់ បើកនាវាដឹកស្បៀង និងសម្ភារសឹកផ្សេងៗពីទីក្រុងភ្នំពេញមកកាន់ទីរួមខេត្តកំពង់ចាម ជា

ញឹកញាប់ទទួលរងការវាយប្រហារដោយកងទ័ពរំដោះខ្មែរក្រហមពីត្រើយម្ខាងៗនៃទន្លេមេគង្គ។ នៅពេលឮសំឡេងម៉ាស៊ីនបើកមកម្តងៗ ខ្ញុំត្រូវរត់ចូលលេណដ្ឋាន ព្រោះមានការប្រយុទ្ធគ្នារវាងទាហានម៉ារីនលន់នល់ជាមួយកងទ័ពរំដោះខ្មែរក្រហម។ នៅពាក់កណ្តាលឆ្នាំ១៩៧៣ កងទ័ពរំដោះខ្មែរក្រហមវាយរំដោះបានពាក់កណ្តាលនៃទីរួមខេត្តកំពង់ចាម និងនៅបន្តប្រយុទ្ធជាមួយទាហានលន់នល់ដែលនៅសេសសល់។ នៅឆ្នាំ១៩៧៤ ខ្ញុំធ្វើការងារនៅកងសាមគ្គី។

បន្ទាប់មកទៀត នៅឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមបង្កើតកងប្រវាស់ដៃដើម្បីជួយប្រមូលស្រូវ និងប្រមូលផលដំណាំផ្សេងៗចែកគ្នាហូប។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបង្កើតសហករណ៍ និងបានបែងចែកប្រជាជនឲ្យធ្វើការងារនៅកងចល័ត។ ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការងារនៅតាមកងចល័តដែលមានទិសដៅលើកទំនប់ត្រួយចេក ស្ថិតនៅឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំត្រូវងើបពីម៉ោង៤ទៀបភ្លឺទៅប្រជុំជួរដើម្បីស្តាប់ផែនការរបស់អង្គការដាក់ឲ្យធ្វើ។ ខ្ញុំចាប់ផ្តើមធ្វើការងារពីម៉ោង៦ព្រឹកដល់ម៉ោង១១ទើបឈប់សម្រាកហូបបបរនៅរោងបាយរួម រួចហើយខ្ញុំត្រូវបន្តធ្វើការងារចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាច។ ខ្ញុំលើកទំនប់ត្រួយចេករយៈពេល៦ខែ ក៏ផ្លាស់ទៅជីកប្រឡាយនៅក្នុងស្រុកជើងព្រៃរយៈពេល៦ខែទៀត។

នៅរដូវប្រូតកាត់ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានអង្គការផ្លាស់ឲ្យមកធ្វើការងារនៅវិហារធំវិញ។ ខ្ញុំត្រូវក្រោកពីម៉ោង៣ទៀបភ្លឺទៅដល់កន្លែងប្រូត ដោយមានសមាជិកចំនួន១៥នាក់ប្រូតស្រូវក្នុង១ហិកតា។ ខ្ញុំ ចាប់ផ្តើមប្រូតពីព្រឹករហូតដល់ម៉ោង១១ ទើបឈប់សម្រាកហូបបបរ។ ខ្ញុំបន្តធ្វើការទៀតនៅម៉ោង១២រហូតដល់ម៉ោង៥ល្ងាច។ ប៉ុន្តែបើប្រូតស្រូវមិនហើយ ខ្ញុំបន្តប្រូតរហូតរួចរាល់ទើបអាចឈប់សម្រាកបាន។ នៅពេលប្រូតរួច ខ្ញុំត្រូវចងកណ្តាប់ស្រូវជាមួយក្រុមកងចល័តផ្សេងទៀត។

នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យរែកដីចាក់លើខ្នងទំនប់ក្នុងមួយថ្ងៃឲ្យបាន២ម៉ែត្រគីប។ នៅដើមឆ្នាំ១៩៧៩ ខ្ញុំបានឮសូរកាំភ្លើងបាញ់គ្នាល្មើយៗ និងឃើញកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមករំដោះប្រជាជនចេញពីការកាប់សម្លាប់របស់ខ្មែរក្រហម។ ខ្ញុំបានរួចផុតពីសេចក្តីស្លាប់ និងបានត្រឡប់មករស់នៅភូមិជាមួយគ្រួសារវិញ។



ទិដ្ឋភាពថតពីលើអាកាសនៅឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មី រើន ៖ អ្នកមើលកុមារនៅក្នុងរបបខ្មែរក្រហម

*ផន ម៉ារី*



មី រើន អាយុ៩៧ឆ្នាំ រស់នៅភូមិពង្រ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ និងផន ម៉ារី អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៤ ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ មី រើន អាយុ៩៧ឆ្នាំ រស់នៅភូមិពង្រ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ ខ្ញុំបានរៀបការជាមួយស្វាមីឈ្មោះ បាន និងមានកូនចំនួន៤នាក់។ នៅក្នុងរបបខ្មែរក្រហម អង្គការបានចាត់តាំងខ្ញុំឲ្យមើលកុមារតូចៗ ដោយសារខ្ញុំមានវ័យចំណាស់មិនអាចទៅធ្វើការងារស្រែចម្ការ ដកស្ទូង ជីកទំនប់លើកប្រឡាយ។

ជារៀងរាល់ថ្ងៃ ម្ដាយដែលមានកូនតូចៗ តែងតែយកកូនរបស់ខ្លួនមកឲ្យខ្ញុំជាអ្នកមើលថែជំនួស ហើយអ្នកទាំងនោះបានចេញទៅធ្វើការងារនៅតាមការដ្ឋាន ឬកងចល័តផ្សេងៗ។ ខ្ញុំមើលក្មេងតូចៗជាច្រើននាក់តាំងពីព្រឹករហូតដល់យប់ ទើបឪពុកម្ដាយក្មេងៗទាំងនោះចេញពីធ្វើការ ហើយមកយកកូនត្រឡប់ទៅផ្ទះវិញ។ ក្មេងៗទាំងនោះមិនមានទឹកដោះសម្រាប់បៅ និងអាហារគ្រប់គ្រាន់ទេ គឺមានតែទឹកបបររាវៗ ហើយថ្ងៃខ្លះទៀតសូម្បីតែបបរក៏គ្មានសម្រាប់ក្មេងទាំងនោះដែរ។ ដោយសារតែការស្រេកឃ្លានអាហារ ក្មេងៗតែងតែយំមិនលោះពេលឡើយ។ ខ្ញុំព្យាយាមលួងលោមក្មេងៗកុំឲ្យយំ ព្រោះបើមេកងខ្មែរក្រហមមកទាន់ឃើញក្មេងយំប្រាកដជាចោទខ្ញុំថាមិនចេះមើលក្មេង ហើយយកខ្ញុំទៅសម្លាប់ចោលមិនខាន។

ខ្ញុំខិតខំធ្វើការងារអស់កម្លាំងកាយ ទោះខ្ញុំមិនមានអាហារសម្រាប់បរិភោគក៏ដោយ។ ពេលខ្ញុំត្រឡប់មកពីមើលក្មេងៗវិញ ខ្ញុំញ័រដៃជើងងងឹតមុខនិងធ្លាក់ខ្លួនឈឺ។ ពេលនោះកូនស្រីរបស់ខ្ញុំបានលាក់ទុកអង្ករមួយក្ដាប់ និងលួចដាំបបរឲ្យខ្ញុំហូប ទើបខ្ញុំបានធូរស្បើយ មានកម្លាំងអាចក្រោកដើររួច។ ដោយសារតែការងារលំបាកនិងមិនមានអាហារគ្រប់គ្រាន់ប្ដីរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ រហូតដល់ស្លាប់។ នៅក្នុងរបបខ្មែរក្រហម អ្នកជំងឺដែលមិនបានទៅធ្វើការងារគឺខ្មែរក្រហមមិនចែករបបអាហារឲ្យហូបឡើយ។

ថ្ងៃមួយ បន្ទាប់មើលក្មេងរួច ខ្ញុំធ្វើដំណើរត្រឡប់ទៅខ្ទមនៅពេលល្ងាចវិញ ស្រាប់ជួបសាកសពដែលមានវ័យប្រមាណជាង២០ឆ្នាំ និងឃើញឈាមហូរ

ស្រោចពេញខ្លួន ដែលខ្ញុំគិតថាខ្មែរក្រហមទើបនឹងសម្លាប់ថ្មីៗ។ ពេលឃើញហេតុការណ៍នេះ ខ្ញុំតក់ស្លុត និងអាណិតដល់យុវជនដែលស្លាប់នោះ។ ខ្ញុំក៏មិនដឹងថាជោគវាសនារបស់ខ្ញុំទៅថ្ងៃខាងមុខនឹងក្លាយទៅជាយ៉ាងណាដែរ។ ទោះបីយ៉ាងណា ខ្ញុំខិតខំធ្វើការងារបន្ថែមទៀតជូនអង្គការ ព្រោះខ្លាចអង្គការយកទៅសម្លាប់ចោល។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំក្លាយទៅជាស្ត្រីមេម៉ាយត្រូវទទួលរ៉ាប់រងចិញ្ចឹមកូនតែឯង។ ខ្ញុំសោកស្តាយចំពោះសមាជិកក្រុមគ្រួសារ និងសាច់ញាតិដែលត្រូវបានខ្មែរក្រហមសម្លាប់ និងស្លាប់ដោយសារជំងឺ និងការអត់អាហារ។ ខ្មែរក្រហមបានបន្សល់នូវបញ្ហាបែកបាក់ក្រុមគ្រួសារ បន្សល់ទុកនូវស្ត្រីមេម៉ាយ ក្មេងកំព្រា និងស្នាមរបួសផ្លូវចិត្តធ្ងន់ធ្ងរដល់រូបខ្ញុំ និងប្រជាជនកម្ពុជា។



ផ្ទះរបស់ មី រើន នៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វត្តខ្នារកកោះ ស្រុកបូរីជលសារ ខេត្តតាកែវ

**ដេង ពង្សរ៉ាស៊ី**



ព្រះចៅអធិការវត្តខ្នារ។
( ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា )



ព្រះវិហារវត្តខ្នារ ស្ថិតនៅក្នុងភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ។
( ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ព្រះវិហារវត្តខ្នារកកោះ ស្ថិតនៅក្នុងភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ នៅតែបន្សល់ទុកស្លាកស្នាមដែលត្រូវបានបំផ្លិចបំផ្លាញដោយខ្មែរក្រហមរហូតមកដល់សព្វថ្ងៃនេះ។ អ្នកភូមិ ពុទ្ធបរិស័ទចំណុះជើងវត្ត ព្រម ទាំងគណៈកម្មការវត្តខ្នារកកោះ បានបោះបង់ព្រះវិហារនេះចោលមួយអន្ទើរ ហើយបាននិងកំពុងកសាងព្រះវិហារថ្មីសន្ទាងមួយ ស្ថិតនៅក្បែរព្រះវិហារចាស់ប្រមាណ២០ម៉ែត្រ ដោយ សារតែព្រួយបារម្ភពីការបាក់ស្រុតនៃអគារព្រះវិហារនេះ។ នៅ ខាងក្នុងព្រះវិហារចាស់ទ្រុឌទ្រោមមួយនេះ មានបន្សល់ទុកព្រះពុទ្ធបដិមាធ្វើពីស៊ី



ម៉ង់ត់ធំមួយភ្នែន និងក្តារមឈូសបាក់បែកធ្វើពីឈើមួយ ស្ថិតនៅពីក្រោយបល្ល័ង្កព្រះ។ ជើងសសរទាំងអស់ដែលទ្រត្រួព្រះវិហារទាំងមូល មានសភាពប្រេះស្រាំខ្លាំង និងបែកជាបំណែកៗ។

ព្រះតេជគុណចៅអធិការវត្ត និងគណៈកម្មការវត្តបានប្រាប់ឲ្យដឹងថា សភាពប្រេះស្រាំទាំងនេះគឺបណ្តាលមកពីជាតិប្រៃនៃអំបិលដែលខ្មែរក្រហមបានស្តុកទុកកាលពីរជ្ជកាលគ្រប់គ្រងដោយ ប៉ុល ពត។ ជញ្ជាំងព្រះវិហារទាំងបួនទិស ក៏ត្រូវបានបាក់ស្រុត និងរបេះដោយដុំៗ។ គំនូរពណ៌នៅតាមជញ្ជាំង និងដំបូលគឺនៅមានសភាពស្រស់ស្អាត ចម្រុះពណ៌ និងច្បាស់ៗ។ ក្រៅពីប្រើប្រាស់ជាឃ្លាំងអំបិល ខ្មែរក្រហមបានប្រើប្រាស់អគារព្រះវិហារនេះជាមន្ទីរពេទ្យ និងកន្លែងដាក់អ្នកជំងឺទៀត។ មិនមានអ្នកជំងឺស្លាប់នៅក្នុងព្រះវិហារនេះច្រើនទេ ហើយសាកសពទាំងនោះត្រូវបានសែងចេញយកទៅកប់ចោលនៅបរិវេណមួយដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីទីតាំងព្រះវិហារ។

នៅក្រោយឆ្នាំ១៩៧៩ ផ្នែកខ្លះនៃព្រះវិហារ ត្រូវបានជួសជុលឡើងវិញ ដើម្បីបម្រើដល់វិស័យព្រះពុទ្ធសាសនាដែលទើបងើបឡើងវិញបន្ទាប់ពីការបំផ្លិចបំផ្លាញរបស់ខ្មែរក្រហម។ បើតាមប្រវត្តិរបស់វត្តខ្នារកកោះដែលរៀបរាប់ដោយព្រះចៅអធិការបានឲ្យដឹងថា បរិវេណវត្តនេះត្រូវបានបង្កើតឡើងនៅលើទីទួលមួយកន្លែងកាលពីឆ្នាំ១៨០៦ ហើយមកដល់ពេលបច្ចុប្បន្នមានអាយុកាល២១៧ឆ្នាំ គ្រប់គ្រងដោយព្រះគ្រូចៅអធិការ១៥ជំនាន់រួចមកហើយ។



ព្រះវិហារវត្តខ្នារ ស្ថិតនៅក្នុងភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោក ផេង ពង្សរ៉ាស៊ី ជួបជាមួយព្រះចៅអធិការ និងគណៈកម្មការវត្តខ្នារ ស្ថិតនៅក្នុងភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្មែរក្រហមចាប់កូនរបស់ខ្ញុំយកទៅសម្លាប់ដោយសារតែស្ទូចត្រី

ហេង វ៉ឡេហៀន



ឡូត ឡៅ អាយុ៨១ឆ្នាំ រស់នៅភូមិដុងអារញ្ញ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឡូត ឡៅ អាយុ៨១ឆ្នាំ រស់នៅភូមិដុងអារញ្ញ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ខ្ញុំមានប្តីឈ្មោះ ងៀម និង មានកូនចំនួន ៦នាក់។ ប្តីរបស់ខ្ញុំស្លាប់តាំងពីមុនរបបខ្មែរក្រហម ដោយសារជំងឺ ហើយខ្ញុំបានក្លាយជាស្ត្រីមេម៉ាយ ចាប់តាំងពីពេលនោះមក។ នៅពេលខ្មែរក្រហមឡើងកាន់អំណាច ខ្មែរក្រហមបានបង្ខំខ្ញុំឲ្យចាកចេញពីភូមិដុងអារញ្ញ។ ខ្ញុំបានផ្ញើរអង្ករខ្លះលើរទេះសេះអ្នកភូមិទុកសម្រាប់ធ្វើស្បៀងអាហារពេលធ្វើដំណើរនៅតាមផ្លូវ។ ចំណែកខ្ញុំ និងកូនៗ រួមទាំងសមាជិកក្រុមគ្រួសារ ត្រូវដើរដោយថ្មើរជើងនៅក្រោមកម្តៅថ្ងៃខែចែត្រក្តៅ ហួតហែង។ ខ្ញុំទៅរស់នៅភូមិនិគម ក្នុងឃុំជ្រោយស្តៅ ស្រុកថ្មគោល ខេត្តបាត់ដំបង។ ពេលទៅដល់ទីនោះដំបូង ខ្ញុំគ្មានផ្ទះសម្រាប់រស់នៅទេ។ ខ្ញុំបានសាងសង់ខ្ទមមួយសម្រាប់ស្នាក់នៅជាមួយកូនៗ ចូលដល់រដូវវស្សា ទឹកជន់លិចខ្ទម ទើបខ្ញុំនាំកូនឡើងទៅរស់នៅតាមចិញ្ចើមថ្នល់ ដែលមានទីទួល។

នៅអំឡុងរបបខ្មែរក្រហម ខ្ញុំត្រូវបានអង្គការចាត់ឲ្យទៅធ្វើការងារដកសំណាប ស្ទូងស្រូវ និងបេះបន្លែឲ្យចុងភៅ។ ចំណែកឯកូនៗរបស់ខ្ញុំពីរនាក់ ខ្ញុំយកទៅផ្ញើទុកជាមួយម្តាយចាស់ជរា ដែលត្រូវបានអង្គការចាត់ឲ្យមើលកុមារតូចៗ ព្រោះគាត់ធ្វើការងារនៅតាមកងចល័តមិនកើត ចំណែកកូនពីរនាក់ទៀតត្រូវអង្គការបញ្ជូនទៅតាមកងចល័ត។ នៅថ្ងៃមួយ កូនរបស់ខ្ញុំឈ្មោះ ប៊ុន សួយ លួចទៅស្ទូចត្រីបានមួយយកមកអាំងហូប ដោយសារតែស្រេកឃ្លានខ្លាំងពេក។ ស្រាប់តែពេលនោះ ឈ្លបខ្មែរក្រហមមកទាន់ក៏ចោទកូនរបស់ខ្ញុំថាខ្លាំង លួចត្រីរបស់អង្គការ។ ឈ្លបខ្មែរក្រហមបានចាប់កូនរបស់ខ្ញុំទៅសម្លាប់ ប៉ុន្តែខ្ញុំមិនបានដឹងថាឈ្លបយកកូនរបស់ខ្ញុំទៅសម្លាប់នៅទីណានោះទេ។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំធ្លាប់ឃើញខ្មែរក្រហមបើកអង្គមីទ្ទិញម្តង ដោយបានហៅប្រជាជនជាច្រើនមកចូលរួម។ នៅក្នុងអង្គមីទ្ទិញ អង្គការបានចាប់

បុរសម្នាក់ដែលលួចស្រឡាញ់គ្នាជាមួយនារីម្នាក់ និងបានបបួលគ្នារត់ ប៉ុន្តែខាងស្រីមិនព្រម។ ពេលនោះខ្មែរក្រហមចាប់បុរសនោះយកមកចងស្លាបសេក និងវាយនៅចំពោះមុខប្រជាជន។ បុរសនោះមិនទាន់ស្លាប់ផង ឈ្លបខ្មែរក្រហមក៏យកកាំបិតវះពោះខេះយកថ្លើមប្រមាត់ចេញក្រៅ។ ខ្ញុំមិនហ៊ានមើលឈ្លបវះពោះបុរសនោះទេ ព្រោះអំពើនោះសាហាវខ្លាំងពេក ហើយខ្ញុំខ្លាចងងឹតមុខដួល។ ក្រោយមក ខ្ញុំឮអ្នកភូមិខ្សឹបខ្សៀវគ្នាថា កងទ័ពវៀតណាមវាយចូលមក ហើយពេលនោះខ្ញុំក៏បានរៀបចំអីវ៉ាន់ទុកជាស្រេច។ នៅពេលវៀតណាមវាយចូលមកដល់កន្លែងខ្ញុំរស់នៅ ខ្ញុំក៏បានចាកចេញពីភូមិនិគមក្នុង ទៅរស់នៅភូមិដុងអារញ្ញវិញ។ ខ្ញុំរស់នៅដុងអារញ្ញមិនបានប៉ុន្មានផង ស្រាប់តែយោធាខ្មែរក្រហមលួចវាយចូលមកក្នុងភូមិ ហើយដុតផ្ទះ និងសម្លាប់ប្រជាជនក្នុងភូមិអស់ជាច្រើននាក់ ក្នុងនោះមានម្តាយក្មេករបស់ខ្ញុំរួមទាំងប្អូនថ្លៃស្រីម្នាក់ត្រូវខ្មែរក្រហមបាញ់សម្លាប់។



ផ្ទះរបស់ ឡូត ឡៅ នៅភូមិដុងអារញ្ញ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្មែរក្រហមបាញ់សម្លាប់ប្តីខ្ញុំ

**រោង ឡៃហៀន**



អន ពី អាយុ៧៥ឆ្នាំ រស់នៅភូមិដុងអារញ្ញ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អន ពី អាយុ៧៥ឆ្នាំ រស់នៅភូមិដុងអារញ្ញ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ប្តីរបស់ខ្ញុំ ឈ្មោះ ប៉ា វ៉ែ។ នៅពេលកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ខ្មែរក្រហមបានប្រកាសតាមវិទ្យុថា ប៉ុល ពត បានចូលមកដល់ទីក្រុងភ្នំពេញហើយ។ ពេលនោះ យោធាខ្មែរក្រហមនៅតាមស្រុក ឡោមព័ទ្ធជុំវិញភូមិដើម្បីយាមល្បាតមិនឲ្យប្រជាជនលួចរត់ទៅប្រទេសថៃឡើយ។ ឪពុករបស់ខ្ញុំរស់នៅស្រុកអារញ្ញ ប្រទេសថៃ បានផ្តាំមកខ្ញុំ និងប្តីឲ្យចូលទៅរស់នៅថៃ ប៉ុន្តែប្តីរបស់ខ្ញុំមិនព្រមទៅ។ ពេលនោះខ្ញុំមានផ្ទៃពោះជិតគ្រប់ខែ ខ្មែរក្រហមជម្លៀសខ្ញុំចេញពីភូមិដុងអារញ្ញ ដោយធ្វើដំណើរថ្មើរជើងជាមួយប្តី និងកូនប្រុសតូចៗ២នាក់ទៀត សំដៅទៅភូមិគោកឃ្មុំ។ ប៉ុន្តែស្រាប់តែខ្ញុំឈឺពោះឆ្លងទន្លេតាមផ្លូវ និងកើតបានកូនស្រីម្នាក់ឈ្មោះ ចយ។ បន្ទាប់ពីអាំងភ្លើងបានមួយយប់ ខ្មែរក្រហមក៏ជម្លៀសខ្ញុំបន្តទៅភូមិរូងជ្រៃ។ នៅទីនោះ ខ្មែរក្រហមបង្កើតសហករណ៍ និងសង់ខ្ទមតូចៗនៅស្របផ្លូវឲ្យខ្ញុំស្នាក់។ នៅក្រោយផ្ទះ មានប្រឡាយទឹក ដែលខ្ញុំអាចដាំដំណាំបាន ប៉ុន្តែខ្ញុំគ្មានសិទ្ធិហូបទេ។ ដោយសារខ្ញុំគ្មានទឹកដោះឲ្យកូនបៅ កូនរបស់ខ្ញុំក៏ស្លាប់បាត់ទៅ។

នៅពេលខ្ញុំផ្លាស់ទៅរស់នៅភូមិរូងជ្រៃ ខ្ញុំចាប់ផ្តើមឈឺគ្រុនញាក់ នៅម៉ោង៩ព្រឹក រាល់ថ្ងៃ។ ខ្ញុំបានសុំថ្នាំចំនួន៦គ្រាប់ពីតាម្នាក់ ហើយជាថ្នូរនឹងថ្នាំនេះ គាត់បានយកត្រី ៦គីឡូពីខ្ញុំ ប៉ុន្តែថ្ងៃនោះប្តីរបស់ខ្ញុំរកត្រីបានតែ៣គីឡូ ហើយនៅសល់៣គីឡូទៀតខ្ញុំសុំជំពាក់គាត់សិន។ ក្រោយពេលលេបថ្នាំនោះរួចខ្ញុំបានធូរស្រាលជាងមុន ប៉ុន្តែខ្ញុំមានជំងឺរាកទៀត។ ពេលនោះខ្មែរក្រហមឲ្យខ្ញុំហូបអង្ករសម្រូប ដូច្នេះពេលរាកចេញមកសុទ្ធតែបាយគ្រាប់ៗ។ ខ្ញុំគិតថាខ្ញុំប្រហែលជាស្លាប់ហើយពេលហ្នឹង។ ប្តីរបស់ខ្ញុំបានដើរកាប់សម្បកឈើមកដាំទឹកឲ្យខ្ញុំផឹកស្រាប់តែជាសះស្បើយ។

ក្រោយមកទៀត ខ្ញុំមានទម្ងន់កូនប្រុសម្នាក់ទៀត។ ក្រោយពេលកើតរួចខ្ញុំដាក់ឈ្មោះ វ៉ាន់ ហើយខ្ញុំក៏យកវាទៅផ្ញើទុកឲ្យយាយចាស់ៗមើល។ យាយៗយោលអង្រឹងទៅមកៗក៏ដាច់ខ្សែធ្លាក់កូនរបស់ខ្ញុំ

ប្រោកនឹងគល់ដើមម្នាក់ត្រូវបំបែកក្បាលៗ ដប់ថ្ងៃក្រោយមកកូនរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺកាន់តែធ្ងន់ ហើយស្លាប់បាត់ទៅៗ នៅសម័យនោះ ខ្ញុំធ្លាប់ឃើញកម្មាភិបាលភូមិភាគពាយ័ព្យឈ្មោះ តា ថ យកស្រីៗកូនកាត់ចិនស្អាតៗទៅដេកជាមួយ មួយយប់ទៅពីរយប់រួចក៏ចាប់យកទៅសម្លាប់ចោលៗ ចំណែកប្ដីរបស់ខ្ញុំត្រូវខ្មែរក្រហមប្រើឲ្យទៅរកត្រី រែកសាច់ជ្រូក រែកសាច់គោ ពីរោងកាប់ជ្រូក កាប់គោ មកដាក់នៅរោងបាយរួមៗ ពេលកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកគ្រប់គ្រងជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ គឺប្រជាជនលែងមានត្រី សាច់នំអន្សម ហូបទៀតហើយ គឺមានតែអំបិលគ្រួសប៉ុណ្ណោះៗ

នៅពេលកងទ័ពវៀតណាមចូលមករំដោះ នៅដើមឆ្នាំ១៩៧៩ ខ្ញុំ និងប្ដីរបស់ខ្ញុំបានត្រឡប់មករស់នៅក្នុងភូមិដុងអារញ្ញវិញៗ មិនយូរប៉ុន្មានខ្មែរក្រហមក៏ចូលមកឡោមព័ទ្ធភូមិរបស់ខ្ញុំ និងវាយចូលភូមិកូបតូចទៀតៗ ពេលនោះ ខ្ញុំនិងប្ដីរត់ទៅព្រំដែនថៃ ហើយ ទាហានថៃក៏ដឹកខ្ញុំនិងប្រជាជនភៀសខ្លួនប្រមាណ១៦,០០០នាក់ តាមឡានទៅទម្លាក់នៅខេត្តព្រះវិហារ និងឲ្យចុះពីលើភ្នំៗ ដៃម្ខាងរបស់ខ្ញុំឱបកូនជាប់នឹងទ្រូង ចំណែកដៃម្ខាងទៀតតោងខ្សែ ចុះពីលើភ្នំវិញៗ នៅតាមផ្លូវចុះពីលើភ្នំ ខ្ញុំដើរជាន់លើឈាមប្រជាជនដែលដើរជាន់មីនផ្ទុះស្លាប់ៗ ពេលចុះពីលើភ្នំ ខ្ញុំឲ្យកូនធំៗដើរពីក្រោយតាមស្នាមដានជើងរបស់ខ្ញុំ ព្រោះខ្លាចកូនដើរជាន់មីនៗ

ខ្ញុំនិងប្ដីធ្វើដំណើរថ្មើរជើងអស់រយៈពេលជាច្រើនខែ ទើបមកដល់ភូមិដុងអារញ្ញវិញៗ ខ្ញុំមកដល់ភូមិមិនបានប៉ុន្មានផង ស្រាប់តែកងទ័ពខ្មែរក្រហមចូលមកក្នុងភូមិម្ដងទៀត ហើយដុតផ្ទះ និងចាប់ប្រុសៗយកទៅសម្លាប់ចោលទាំងអស់ៗ ខ្ញុំស្រវាចាប់ដៃប្ដីរបស់ខ្ញុំឲ្យរត់ទៅជាមួយគ្នា ប៉ុន្តែចាប់មិនជាប់ៗ ខ្ញុំបានរត់ចេញពីភូមិជាមួយកូន និងអ្នកភូមិទៅដល់ភូមិកូបតូចៗ នៅពេលយប់មានអ្នកភូមិដែលរត់មកតាមក្រោយ បានស្រែកប្រាប់ខ្ញុំថា «ប្ដីឯងត្រូវខ្មែរក្រហមចាប់បាន និងបាញ់ចោលនៅស្ពានទី១ » ហើយៗ គ្រាន់តែឮពាក្យនេះភ្លាម ខ្ញុំតក់ស្លុតទន់ដៃជើងដើរមិនរួច ហើយក៏ដួលទៅលើដីៗ ខ្ញុំបានត្រឡប់ចូលភូមិធ្វើបុណ្យខួបទិសឲ្យប្ដីៗ ពេលនោះគ្មានអ្នកភូមិណាហ៊ានមកហែរសពប្ដីខ្ញុំទេ ព្រោះម្នាក់ៗត្រៀមរត់ខ្លាចខ្មែរក្រហមលួចចូលមកបាញ់ប្រហារម្ដងទៀតៗ ក្រោយពីធ្វើបុណ្យរួច ខ្ញុំបន្តរស់នៅដុងអារញ្ញមកដល់សព្វថ្ងៃៗ



ផ្ទះរបស់ អន ពី នៅភូមិដុងអារញ្ញ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# កម្មសិក្សាទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

*ឈុំ រ៉ា និង ផុន ស្រីពេជ្រ*






ទីតាំងប្រវត្តិសាស្ត្រ និងទេសភាពនៅអន្លង់វែង ថតដោយ ផុន ស្រីពេជ្រ មកពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និង ឈុំ រ៉ា មកពីមជ្ឈមណ្ឌលឯកសារកោះថ្ម អំឡុងពេលចុះកម្មសិក្សាទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣។ (ឈុំ រ៉ា និង ផុន ស្រីពេជ្រ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ ផុន ស្រីពេជ្រ មកពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និង ឈុំ រ៉ា មកពីមជ្ឈមណ្ឌលឯកសារកោះថ្ម បានចុះកម្មសិក្សាទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលមានទីតាំងស្ថិតនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ គោលបំណងនៃការចុះកម្មសិក្សានេះ ដើម្បីឲ្យបុគ្គលិកសិក្សាឈ្វេងយល់អំពីកិច្ចការដែលមជ្ឈមណ្ឌលនីមួយៗកំពុងអនុវត្ត និងសិក្សាពីទីតាំងប្រវត្តិសាស្ត្រសំខាន់ៗដែលបានបន្សល់ទុកពីសម័យខ្មែរក្រហម និងផ្លាស់ប្តូរគំនិតដើម្បីអភិវឌ្ឍន៍ការងារនៅតាមការិយាល័យរបស់ខ្លួន។

ស្ងួត វិចិត្រ បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅរង់ចាំទទួលស្វាគមន៍យើង និងណែនាំយើងអំពីកិច្ចការរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ នៅថ្ងៃបន្ទាប់ វិចិត្រ បានបែងចែកក្រុមការងារដើម្បីរៀបចំដាក់តាំងពិព័រណ៍រូបថតនៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅលើកំពូលភ្នំដងរែក។ ក្រុមការងារប្រើរយៈពេល២ម៉ោង៣០នាទី ដើម្បីសាកល្បងដំឡើងរូបថតនៅលើរនងដែកទ្រដោយជើងសសរកប់ចូលទៅក្នុងដី។

ឆ្លៀតឱកាសនោះ វិចិត្រ បានរៀបរាប់ប្រាប់យើងអំពីការចាប់ផ្តើមរៀបចំបង្កើតមជ្ឈមណ្ឌល

សន្តិភាពអន្លង់វែងដំបូង នៅក្នុងឆ្នាំ២០១៨។ វិចិត្រក៏បានបង្ហាញអំពីប្រវត្តិសាស្ត្រសំខាន់ៗនៅក្នុងតំបន់អន្លង់វែង ដែលជាចំណុចចាប់ផ្តើមធ្វើឲ្យប្រទេសកម្ពុជាមានសុខសន្តិភាពពេញបរិបូណ៌។ បន្ទាប់មកក្រុមការងាររបស់យើងបានចុះកម្មសិក្សានៅ ទីតាំងប្រវត្តិសាស្ត្រសំខាន់ៗមួយចំនួន ដូចជា៖

១) បឹងអន្លង់វែង ឬបឹងអូរជីក ឬ បឹង តាម៉ុក។ បឹងតាម៉ុក មានចម្ងាយប្រមាណជា២០០ម៉ែត្រពីរង្វង់មូល ស្រុកអន្លង់វែង។ បឹងនេះមានទំហំ៤១៧ ហិកតា និងសម្បូរទៅដោយត្រីតូចធំជាច្រើនប្រភេទ។ នៅពេលតំបន់អន្លង់វែងមិនទាន់ចូលសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ប្រជាជននិងអតីតខ្មែរក្រហមនៅតំបន់នោះ រស់នៅពឹងផ្អែកទៅលើបឹងនេះដែលជាប្រភពអាហារ និងទឹកសម្រាប់ប្រើប្រាស់ដ៏សំខាន់។ តាមសម្តី អ្នករត់ម៉ូតូឌុបម្នាក់ប្រាប់យើងថា តាម៉ុក បានចិញ្ចឹមក្រពើពណ៌សមួយក្បាលនៅក្នុងបឹងនេះ ប៉ុន្តែសព្វថ្ងៃមិនមានប្រជាជនណាម្នាក់បានឃើញក្រពើនេះបង្ហាញខ្លួនឡើយ។

២) ផ្ទះតាម៉ុក សព្វថ្ងៃគឺជាសារមន្ទីរផ្ទះ តាម៉ុក។ ផ្ទះនេះមានចម្ងាយផ្លូវប្រហែលជា២គីឡូម៉ែត្រពីរង្វង់មូលស្រុកអន្លង់វែង។ ទៅដល់ទីនោះយើងឃើញឡានចាស់មួយគ្រឿងដែលសេសសល់តែទ្រង់ទ្រាយប៉ុណ្ណោះ។ ឡាននេះសម្រាប់ផ្សាយវិទ្យុចល័តរបស់ខ្មែរក្រហម ហើយនៅជិតឡាននេះ គឺមានទ្រុងដាក់អ្នកទោសចំនួន ២ របស់ តាម៉ុក។ តាម៉ុក មានផ្ទះចំនួន ៤ ស្ថិតនៅក្នុងភូមិអភិវឌ្ឍន៍ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ផ្ទះ ទី១) សង់អំពីឈើប្រក់ហ្វីប្រូ។ ផ្ទះ ទី២) យើងសង្កេតឃើញមានរូបគំនូរប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ និងផែនទីប្រទេសកម្ពុជានៅតាមជញ្ជាំង។ ផ្ទះ ទី៣) គឺសម្រាប់ទទួលអ្នកដំណើរមកពីចម្ងាយ និងផ្ទះ ទី៤) គឺជាកន្លែងហូបបាយ និងកន្លែងសម្រាប់ចុងភៅរបស់ តាម៉ុក ស្នាក់នៅ។

៣) កន្លែងដុតខ្មោច ប៉ុល ពត មានទីតាំងស្ថិតនៅលើភ្នំដងរែក ក្នុងភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ទីតាំងនេះមានចម្ងាយ



ទីតាំងប្រវត្តិសាស្ត្រ និងទេសភាពនៅអន្លង់វែង ថតដោយ ថុន ស្រីពេជ្រ មកពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និង ឈុំ វ៉ា មកពីមជ្ឈមណ្ឌលឯកសារកោះថ្ម អំឡុងពេលចុះកម្មសិក្សាទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣។
(ឈុំ វ៉ា និង ថុន ស្រីពេជ្រ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







ទីតាំងប្រវត្តិសាស្ត្រ និងទេសភាពនៅអន្លង់វែង ថតដោយ ថុន ស្រីពេជ្រ មកពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និង ឈុំ វ៉ា មកពីមជ្ឈមណ្ឌលឯកសារកោះថ្មអំឡុងពេលចុះកម្មសិក្សាទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣។
(ឈុំ វ៉ា និង ថុន ស្រីពេជ្រ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

១៣គីឡូម៉ែត្រពីរដ្ឋធានីមូលស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ហើយសាកសពប៉ុល ពត ត្រូវបានដុតដោយសំបកកង់ ឡាននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៨។

៤) កន្លែងកាត់ទោស ប៉ុល ពត លើផ្ទៃទំហំ ០.៤៤៨ ហិកតា ស្ថិតនៅភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលមានចម្ងាយ ១៤គី ឡូម៉ែត្រពីរដ្ឋធានីមូលស្រុកអន្លង់វែង នៅជិតច្រកព្រំដែនជាំ- ស្រងាំ។

៥) កន្លែងដុតខ្មោច សុន សេន និងក្រុមគ្រួសារ ស្ថិតនៅភូមិស្រះឈូក ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សុន សេន និងក្រុមគ្រួសារ ត្រូវបានសម្លាប់នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៧។

៦) ផ្ទះតាម៉ុក លើភ្នំដងរែក ត្រូវបានសាងសង់ឡើងនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៥។ ផ្ទះតាម៉ុក ស្ថិតនៅលើខ្នងភ្នំដងរែក ដោយយើងធ្វើដំណើររយៈពេល ១ម៉ោងចេញពីមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅទល់មុខបឹងអន្លង់វែង ឬបឹងតាម៉ុក។

សួត វិចិត្រ បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងផ្តល់ព័ត៌មានថា ផ្ទះតាម៉ុកបានប្រែក្លាយទៅជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅឆ្នាំ២០១៤។ វិចិត្រ បន្តថា ដំបូងផ្ទះនេះត្រូវភ្លើងឆេះអស់ ហើយក្រោយមកមជ្ឈមណ្ឌលឯកសារកម្ពុជាបានសាងសង់ឡើងវិញដូចទៅនឹងទ្រង់ទ្រាយដើម និងប្រែក្លាយជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

តាមរយៈកម្មសិក្សានេះ យើងសង្កេតឃើញថា នៅលើភ្នំដងរែកគឺជាកន្លែងប្រមូលផ្តុំទៅដោយទីតាំងប្រវត្តិសាស្ត្រ និងកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម។ ទីតាំងប្រវត្តិសាស្ត្រនេះនៅសេសសល់ភស្តុតាងរហូតមកដល់សព្វថ្ងៃ ដែលអាចឲ្យយុវជនខ្មែរមកសិក្សាឈ្វេងយល់ដើម្បីទប់ស្កាត់កុំឲ្យរបបនេះវិលត្រឡប់

មកម្តងទៀត។ ចំណែកប្រជាជនភាគច្រើននៅក្នុងស្រុកអន្លង់វែងប្រកបរបរកសិកម្ម ពិសេសដាំឡូងមីដើម្បីប្រមូលលក់ឲ្យឈ្មួញថៃ។ ទោះបីយ៉ាងណាអន្លង់វែង ស្ថិតនៅដាច់ស្រយាល ហើយយើងត្រូវជិះឡានក្រុងរយៈពេល១០ម៉ោងពីទីក្រុងភ្នំពេញទើបមកដល់តំបន់នេះ។ ចំណែកស្ថានភាពផ្លូវចូលទៅកាន់តំបន់ប្រវត្តិសាស្ត្រមួយចំនួនមានការលំបាក និងមានផ្លូវតូចចង្អៀតមិនអាចធ្វើដំណើរតាមម៉ូតូបានឡើយ ដូច្នេះហើយទើបយើងខកខានមិនទៅមើលតំបន់ប្រវត្តិសាស្ត្រក្បាលទន្សោង ដែលជាកន្លែងលាក់ខ្លួនរបស់ ប៉ុល ពត។









ទីតាំងប្រវត្តិសាស្ត្រ និងទេសភាពនៅអន្លង់វែង ថតដោយ ផុន ស្រីពេជ្រ មកពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និង ឈុំ វ៉ា មកពីមជ្ឈមណ្ឌលឯកសារកោះថ្ម អំឡុងពេលចុះកម្មសិក្សាទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣។
(ឈុំ វ៉ា និង ផុន ស្រីពេជ្រ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# កម្មសិក្សាថ្នាក់មូលដ្ឋាននៅមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម

**ភា រស្មី**



*ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តកំពង់ចាម។ (ភា រស្មី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៣ ខ្ញុំបានចុះកម្មសិក្សាថ្នាក់មូលដ្ឋានចំនួន២យប់ ៣ថ្ងៃ ទៅកាន់មជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។ អំឡុងពេលចុះកម្មសិក្សា ខ្ញុំបានចុះទៅទីកន្លែង និងតំបន់ប្រវត្តិសាស្ត្រមួយចំនួន ដូចជា ទំនប់ជ្រោយចេក, ព្រលានយន្តហោះ, ភ្នំប្រុស, ប្រាសាទនគរបាជ័យ, ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តកំពង់ចាម, វត្តសិម្ពលីវនារាម ហៅវត្តរកាគយ, ទីតាំងចេតិយតម្កល់អដ្ឋិធាតុជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩) និងការចុះទៅកាន់សហគមន៍ចាម។

## ១) ទំនប់ទឹកជ្រោយចេក

ទំនប់ទឹកជ្រោយចេកស្ថិតនៅក្នុងភូមិគ្រោល ឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ទំនប់ទឹកនេះសាងសង់ឡើងដើម្បីរក្សាទឹកទុកធ្វើស្រែ និងចម្ការ។ បន្ថែមជាងនេះទៅទៀត ប្រជាជននៅក្នុងតំបន់នោះអាចធ្វើការនេសាទ និងរកបន្លែផ្សេងៗដែលបានដុះនៅក្នុងទំនប់ដើម្បីយកមកចិញ្ចឹមជីវិតប្រចាំថ្ងៃ ក៏ដូចជាលក់នៅលើទីផ្សារ។ ទំនប់ទឹកជ្រោយចេកចាប់ផ្តើមសាងសង់ឡើងនៅឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ដោយមានកម្មាភិបាលខ្មែរក្រហមជាអ្នកគ្រប់គ្រង។



ទំនប់ទឹកជ្រោយបេក ស្ថិតនៅក្នុងភូមិគ្រោល ឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ភា រស្មី/មជ្ឈមណ្ឌលឯកសារកម្ពុជា)





ព្រលានយន្តហោះ មានទីតាំងស្ថិតនៅភូមិអំពិល ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ភា រស្មី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជនជាច្រើននាក់បានស្លាប់បាត់បង់ជីវិតនៅពេលលើកទំនប់នេះដោយសារមិនមានអាហារបរិភោគគ្រប់គ្រាន់ មានជំងឺហើយគ្មានថ្នាំព្យាបាល និងធ្វើការហួសកម្លាំង។

## ២) ព្រលានយន្តហោះ

ព្រលានយន្តហោះ ខេត្តកំពង់ចាម មានទីតាំងស្ថិតនៅភូមិអំពិល ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ព្រលានយន្តហោះខេត្តកំពង់ចាម បង្កើតឡើងតាំងពីសម័យសង្គមរាស្ត្រនិយម សម្តេចព្រះនរោត្តម សីហនុ។ ក្រោយមកនៅក្នុងសម័យ លន់ នល់ ទីតាំងប្រលានយន្តហោះត្រូវបានទាហាន លន់ នល់ ធ្វើជាទីតាំងមូលដ្ឋានទ័ព។ ចាប់តាំងពីរបបខ្មែរក្រហមដួលរលំមក ព្រលានយន្តហោះនេះបានបញ្ឈប់ដំណើរការរហូតដល់បច្ចុប្បន្ន។ សព្វថ្ងៃនេះ ប្រជាជនបានយកបរិវេណព្រលានយន្តហោះធ្វើជាចម្ការដាំដំណាំ និងឈូសឆាយ ជួសជុលផ្លូវសម្រាប់ធ្វើដំណើរ។

## ៣) ភ្នំប្រុស

បើតាមប្រសាសន៍របស់ចាស់ព្រឹទ្ធាចារ្យនៅក្នុងតំបន់បានឲ្យដឹងថា ភ្នំប្រុសបានបង្កើតឡើងអំឡុងពេលសម័យអាណានិគមន៍បារាំង ឬក៏មុននោះទៅទៀត។ នៅលើភ្នំប្រុសមានចេតិយមួយដែលនៅលើកំពូលចេតិយមានព្រហ្មមុខបួនធ្វើអំពីស្ពាន់ និងមានត្បូងមានតម្លៃជាច្រើនទៀត។ នៅក្នុងសម័យ លន់ នល់ នៅលើភ្នំប្រុស គឺជាកន្លែងដាក់កាំភ្លើងធ្លោង និងគ្រាប់បែករបស់ទាហាន លន់ នល់ ដើម្បីបាញ់ផ្លោងសំដៅទៅកាន់ក្រុមខ្មែរក្រហមស្ថិតនៅឃុំគគរ និងស្រុកកោះសូទិន។

## ៤) ប្រាសាទនគរបាជ័យ

ប្រាសាទនគរបាជ័យ បានកសាងឡើងក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ ដើម្បីឧទ្ទិសចំពោះពុទ្ធសាសនាមហាយាន។ នៅក្នុងសម័យសង្គ្រាម ប្រជាជនមួយចំនួនបានគាស់យកថ្មនៅខ្លោងទ្វារប្រាសាទទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងៗ។ ក្រោយសម័យខ្មែរក្រហម ទីតាំងប្រាសាទនគរបាជ័យ ក៏ជាទីតាំង



ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តកំពង់ចាម។
(ភារស្មី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្រាប់តម្កល់អដ្ឋិធាតុជនរងគ្រោះដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម។

### ៥) ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តកំពង់ចាម

ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តកំពង់ចាម បានបង្កើតឡើងនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ដោយមានកិច្ចសហការរវាងក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ទីតាំងរបស់ការិយាល័យគឺស្ថិតនៅក្នុងបរិវេណ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម។ គោលបំណងដែលបង្កើត ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមនេះឡើង គឺដើម្បីធ្វើជាកន្លែងសិក្សាស្រាវជ្រាវ កន្លែងតម្កល់ឯកសារ ប្រវត្តិសាស្ត្រខ្មែរក្រហម ទុកឲ្យក្មេងជំនាន់ក្រោយបានសិក្សារៀនសូត្រ។ នៅក្នុងការិយាល័យស្រាវជ្រាវ មានតម្កល់ឯកសារជា ឯកសារក្រដាស ដែលរក្សាទុកនៅក្នុងទូឯកសារ ឯកសារជារូបភាព ដែលបង្ហាញតាមរយៈការតាំងពិព័រណ៍ និងឯកសារសំឡេងដែលមានទាំងចម្រៀង និងភាពយន្តឯកសារ។ បន្ថែមលើនេះ ការិយាល័យក៏មានបន្ទប់ប្រជុំអនឡាញមួយទៀតដែលស្ថិតនៅជាប់បន្ទប់ធំ។



ប្រាសាទនគរបាជ័យ។
(ភារស្មី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

### ៦) វត្តសិម្ពលីវនារាម ហៅ វត្តរកាគយ

វត្តរកាគយ ស្ថិតនៅក្នុងភូមិរកាគយ (ក) ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម។ ក្នុងសម័យលន់ នល់ នៅក្នុងវត្តរការគយគឺជាទីកន្លែងលាក់ខ្លួនរបស់កងទ័ពបដិវត្តន៍ខ្មែរក្រហម ដែលនៅចាំស្ទាក់



ភ្នំប្រុស ។ (ការស្មើ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បាញ់ទាហានលន់នល់ ដែលធ្វើដំណើរតាមផ្លូវទឹក។ នៅក្នុងសម័យខ្មែរក្រហម បរិវេណវត្តរកាគយ ត្រូវបានខ្មែរក្រហមយកទៅធ្វើជាឃ្លាំងសម្រាប់ដាក់ស្បៀងអាហារ និងសម្ភារប្រើប្រាស់ផ្សេងៗ។

**៧) ទីតាំងចេតិយតម្កល់អដ្ឋិធាតុជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩)**

នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ មជ្ឈមណ្ឌលឯកសារកម្ពុជា បានសហការជាមួយគណៈឃុំគគរ ដើម្បីសង់ចេតិយតម្កល់អដ្ឋិធាតុមួយឡើងនៅក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ចេតិយនេះសង់ឡើងដើម្បីឲ្យកូនចៅជំនាន់ក្រោយមានការចងចាំអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងសម័យខ្មែរក្រហម និងជាកន្លែងរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម។ បើតាមប្រសាសន៍របស់លោក តុង សុភា ដែលជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានឲ្យដឹងថា នៅក្នុងសម័យខ្មែរក្រហម ទីកន្លែងសង់ចេតិយនេះគឺជាដីស្រែរបស់អង្គការ។ អង្គការបានបញ្ជាប្រជាជនឲ្យមកធ្វើស្រែជាក្រុម និងយកទិន្នផលទាំងអស់ដាក់ធ្វើជាកម្មសិទ្ធិរួម។ នៅពេលរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩ ប្រជាជននាំគ្នាសាងសង់របងនៅទីតាំងនេះ ដើម្បីការពារក្រុមខ្មែរក្រហមដែលរត់ចូលព្រៃ កុំឲ្យចូលមកធ្វើបាបប្រជាជនក្នុងភូមិ។ ចំពោះឆ្អឹងសាកសពជនរងគ្រោះ ដែលរាយនៅជិតៗនោះ ប្រជាជនបានប្រមូលយកទៅតម្កល់នៅក្នុងវត្តនគរបាជ័យ រហូតដល់ឆ្នាំ១៩៨៥ ទើបបញ្ជូនទៅតម្កល់នៅលើភ្នំប្រុស ភ្នំស្រីវិញ។

**៨) ការចុះទៅកាន់សហគមន៍ចាម**

នៅសហគមន៍ចាម ខ្ញុំបានចូលទៅមើលការត្បាញរបស់សហគមន៍ចាម នៅស្រុកកោះសូទិន។ ស្មាន ស្រីយ៉ះ បានឲ្យដឹងថា គាត់ចេះត្បាញហូលតាមម្តាយរបស់គាត់។ ការត្បាញហូលគឺមានច្រើនជំនាន់មកហើយ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនចាមទាំងអស់ដែលរស់នៅខាងស្រុកកោះសូទិន

ត្រូវបានជម្លៀសឲ្យទៅខេត្តផ្សេង ហើយការត្បាញហូលត្រូវបានផ្អាកជាបណ្តោះអាសន្ន។ ក្រោយរបបខ្មែរក្រហមដួលរលំ ប្រជាជនចាមជាច្រើននាក់បានស្លាប់ ហើយអ្នកនៅរស់បានត្រឡប់មករស់នៅភូមិកំណើត នៅខេត្តកំពង់ចាមវិញ។ នៅក្នុងភូមិទី១៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម មានជនជាតិចាមត្បាញហូលជាច្រើនគ្រួសារ ប៉ុន្តែក្រោយមកដោយសារមិនសូវមានទីផ្សារទើបប្រជាជនមួយចំនួនឈប់ត្បាញ។ ស្មាន ស្រីយ៉ះ បានបន្តថា ក្នុងមួយអាទិត្យគាត់អាចត្បាញហូលបានមួយក្បិន បើគិតជាសំពត់បានពីរ ប៉ុន្តែក្នុងមួយអាទិត្យនេះគឺគាត់មិនគិតពីពេលវេលាជ្រលក់ពណ៌ឬស្រាវសរសៃសូត្រទេ។ សព្វថ្ងៃនេះ ស្មាន ស្រីយ៉ះ បានសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងគម្រោងសូត្រចាម ដើម្បីយកផលិតផលដែលគាត់ត្បាញបាន ទៅលក់នៅក្រៅប្រទេស។

## ចំណេះដឹងដែលទទួលបានពីកម្មសិក្សា

នៅក្នុងពេលចុះកម្មសិក្សា ខ្ញុំមានការចាប់អារម្មណ៍ជាច្រើនកិច្ចការងារ ជាពិសេសការងាររបស់មជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។ ខ្ញុំសង្កេតឃើញថា មជ្ឈមណ្ឌលនេះមានការរៀបចំបានល្អ មានទាំងការតាំងពិព័រណ៍រូបភាព ឯកសារក្រដាសនៅក្នុងទូសៀវភៅ និងសម្ភារពីបុរាណមួយចំនួនទៀត។ ចំណែកការរៀបចំការិយាល័យមានភាពទាក់ទាញ បរិស្ថានជុំវិញល្អ ដែលស័ក្តិសមជាកន្លែងធ្វើការ រក្សាឯកសារ កន្លែងស្រាវជ្រាវ និងកន្លែងអប់រំ។ អំឡុងពេលចុះកម្មសិក្សា ខ្ញុំបានដឹងអំពីការងារមួយចំនួនដែលខាងមជ្ឈមណ្ឌលឯកសារកំពង់ចាមអនុវត្តជារៀងរាល់ខែ។ សកម្មភាពមួយចំនួនមានភាពស្រដៀងគ្នា និងមានភាពខុសគ្នាបន្តិចបន្តួច ហើយភាពខុសគ្នានេះអាចជាបទពិសោធន៍ថ្មីមួយទៀតសម្រាប់ខ្ញុំធ្វើការអភិវឌ្ឍន៍។ បន្ថែមពីនេះទៅទៀត ការចុះទៅកាន់ទីតាំងផ្សេងៗនៅក្នុងខេត្តកំពង់ចាម បានធ្វើឲ្យខ្ញុំដឹងរឿងរ៉ាវនានានៅក្នុងតំបន់នេះ ពិសេសរឿងរ៉ាវជនរងគ្រោះក្នុងសម័យខ្មែរក្រហម និងទីតាំងប្រវត្តិសាស្ត្រ។ នៅពេលដែលខ្ញុំចុះទៅជួបប្រជាជននៅតាមភូមិ នៅខេត្តកំពង់ចាម ទើបខ្ញុំដឹងថាមានឈ្មោះ ភូមិ ឃុំមួយចំនួនខ្ញុំធ្លាប់បានឮពីមុនមកតាមរយៈការរៀបរាប់របស់ប្រជាជនក្នុងខេត្តព្រៃវែងដែលធ្លាប់មករស់នៅកំពង់ចាម។ ចំពោះសាច់រឿងមួយចំនួន ហាក់មានភាពស្រដៀងគ្នា បើទោះបីនៅក្នុងសម័យខ្មែរក្រហមស្ថិតនៅក្នុងភូមិភាគផ្សេងគ្នាក៏ដោយ។ រឿងរ៉ាវមួយចំនួនទៀតដែលខ្ញុំបានដឹង គឺមកពីបទសម្ភាសន៍កន្លងមក ហើយខ្ញុំយល់ដឹងកាន់តែច្បាស់ថែមទៀត នៅពេលដែលខ្ញុំចុះមកជួបប្រជាជននៅមូលដ្ឋានផ្ទាល់។



ទីតាំងចេតិយតម្កល់អដ្ឋិធាតុជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩)។ (ភាំ រស្មី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ស្ត្រីជនជាតិចាម នៅស្រុកកោះសូទិន ខេត្តកំពង់ចាម កំពុងត្បាញហូល។
(ភា រស្មី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# គណៈប្រតិភូខេត្តត្បូងឃ្មុំធ្វើទស្សនកិច្ចសិក្សា

## និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម X-16

*ឈុំ រ៉ា*



គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម x-16 ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ, លោក អ៊ុន ពៅសម្បត្តិ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ ដោយមានការចូលរួមសហការពីសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តត្បូងឃ្មុំបានដឹកនាំយុវជនចំនួន ៣០០នាក់ មកទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្មX-16 ក្នុងឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

ជាកិច្ចចាប់ផ្តើមលោក ផេង ពង្ស៉្រាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាបានអញ្ជើញ ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ នៃគណៈអភិបាលខេត្តត្បូងឃ្មុំ លោក អ៊ុន ពៅសម្បត្តិ ប្រធានមន្ទីរអប់រំខេត្តត្បូងឃ្មុំ ព្រមទាំងយុវជនកាយរិទ្ធិកាកបាទក្រហម សហភាពសហព័ន្ធយុវជន



គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម x-16 ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







កម្ពុជា និងក្រុមយុវជនចូលទស្សនាពិព័រណ៍រូបថតនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម ដោយចាប់ផ្តើមពីបណ្តុំរូបថតនៃសង្គ្រាមនៅក្នុងប្រទេសកម្ពុជានៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ដោយចាប់ផ្តើមចេញពីតំបន់កោះថ្ម, បណ្តុំរូបថតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), បណ្តុំរូបថតនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩, បណ្តុំរូបថតភ័ស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) បណ្តុំរូបគំនូរដែលសមមិត្ត ហ៊ុន សែន (សម្តេចតេជោ ហ៊ុន សែន) និងយុទ្ធមិត្ត៤រូបចាកចេញទៅប្រទេសវៀតណាមដើម្បីរៀបចំកម្លាំងវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងផែនទីបង្ហាញផ្លូវដែលសមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៤រូបបានចាកចេញពីបន្ទាយយោធានៅភូមិកោះថ្មទៅតំបន់ព្រំដែនអាងដាច់ដើមត្រយឹង (X-16) និងទីតាំងមួយចំនួននៅក្នុងស្រុកឡុកនិញ ខេត្តសុងប៊ែ ប្រទេសវៀតណាម និងការបង្កើតអង្គភាព១២៥ ដែលជាកងកម្លាំងប្រដាប់

អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាដំបូងបង្អស់ ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨។

បន្ទាប់ពីបានទស្សនាពិព័រណ៍រូបភាពនៅមជ្ឈ-មណ្ឌលឯកសារកោះថ្មរួចមក គណៈប្រតិភូ និងយុវជនបានបន្តដំណើរទៅកាន់តំបន់កោះថ្ម X-16 ដើម្បីរៀបចំវេទិកាថ្នាក់រៀននៅអគារមិត្តភាព។ ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ បានមានប្រសាសន៍អំពីការតស៊ូរបស់សម្តេចតេជោ ហ៊ុនសែន ជាការប្តូរសាច់ស្រស់ឈាមស្រស់ ដើម្បីទទួលបានសុខសន្តិភាព និងស្ថិរភាព។ នៅក្នុងភាពជាអ្នកដឹកនាំល្អ អ្នកដឹកនាំត្រូវមានតួនាទីដើរមុនគេជានិច្ច រៀបចំផែនការជាមុនដើម្បីឲ្យការងារមានភាពប្រសើរ។ ជាពិសេសអ្នកដឹកនាំល្អត្រូវតែគោរពតួនាទីជានិច្ច ត្រូវហ៊ានលះបង់ជាធំ។

ជាកិច្ចបន្តលោក ផេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ដល់យុវជនមានដូចខាងក្រោម ៖

- វាស់ស្ទង់ចំណេះដឹងមុនវេទិកាចាប់ផ្តើម ដោយប្រើប្រាស់កម្រងសំណួរវាស់ស្ទង់មតិ។
- ចែកចាយទស្សនាវដ្តីស្វែងរកការពិតដល់យុវជនទាំងអស់។
- បទបង្ហាញ និងពន្យល់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)៖ គោលនយោបាយ៨ចំណុចរបស់របបកម្ពុជាប្រជាធិប-តេយ្យ (១៩៧៥-១៩៧៩)។

លោក ផេង ពង្សរ៉ាស៊ី បានពន្យល់សិស្សានុសិស្សថា នៅដំណាក់កាលដំបូងយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ និងចាប់ផ្តើមជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងប្រមាណ២លាននាក់ក្រោមមូលហេតុផ្សេងៗ ដូចជា សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកលើទីក្រុង ប្រជាជនចេញទៅយកស្បៀងអាហារនៅទីជនបទ និងបំបែកចារកិច្ចរបស់ខ្មាំងជាដើម។ ការជម្លៀសដោយបង្ខំនេះបានបណ្តាលឲ្យប្រជាជនរាប់ពាន់នាក់ ជាពិសេសកុមារ មនុស្សចាស់ជរា និងអ្នកជំងឺបានស្លាប់នៅតាមផ្លូវ។



គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម x-16 ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្ត្រីមានផ្ទៃពោះជាច្រើនបានស្លាប់នៅពេលសម្រាលកូនដោយសារគ្មានថ្នាំសង្កូវ ឬសេវាសុខាភិបាល។ ក្មេងៗបានវង្វេងបាត់ពីឪពុកម្តាយ។ ប្រជាជនភាគច្រើនមិនដឹងថា តើនឹងមានអ្វីកំពុងតែកើតឡើង ទេ។ លោក ផេង ពង្សរ៉ាស៊ី បានបន្តថាការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី២ គឺខ្មែរក្រហមបានជម្លៀសប្រជាជននៅភូមិភាគបូព៌ា រួមមាន ខេត្តស្វាយរៀង ខេត្តព្រៃវែង និងផ្នែកខ្លះនៃខេត្តកំពង់ចាមដែលស្ថិតនៅត្រើយខាងកើតទន្លេមេគង្គ (បច្ចុប្បន្ន ខេត្តត្បូងឃ្មុំ) ទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគកណ្តាលបន្ទាប់ពីខ្មែរក្រហមបានចោទប្រកាន់មេដឹកនាំ និងកម្មាភិបាលនៅភូមិភាគបូព៌ាក្បត់ដោយបានចូលរួមជាមួយប្រទេសវៀតណាម នៅចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។ ការជម្លៀសដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគកណ្តាលនេះបានបណ្តាលឲ្យប្រជាជនភូមិភាគបូព៌ាជាច្រើន បានស្លាប់ដោយសារការយកទៅសម្លាប់ ដោយសារជំងឺ និងអត់អាហារ។ ទី២) ការលុបបំបាត់លុយ និងផ្សារ។ ទី៣) ការលុបបំបាត់ទ្រព្យសម្បត្តិឯកជន។ ទី៤) ការលុបបំបាត់ប្រពៃណី សាសនា ទំនៀមទម្លាប់ និងបំផ្លាញសាលារៀន វត្តអារាម និងកន្លែងលក់ដូរផ្សេងៗ។ ទី៥) ខ្មែរក្រហមបានបង្កើតសហករណ៍ និងការដ្ឋានការងារដែលតម្រូវឲ្យប្រជាជនទាំងអស់ធ្វើស្រែចម្ការ និងលើកទំនប់ធំៗ។ ទី៦) ខ្មែរក្រហមបានសម្លាប់អ្នកចេះដឹង អតីតទាហាន លន់ នល់ និងជនជាតិចាម វៀតណាម និង ចិន។ ទី៧) ខ្មែរក្រហមបានបង្កើតមន្ទីរឃុំឃាំងជិត២០០កន្លែង ដើម្បីឃុំឃាំងប្រជាជនដែលខ្លួនចោទថាក្បត់ ហើយប្រជាជនទាំងនោះភាគច្រើនត្រូវបានសម្លាប់យ៉ាងសាហាវ។ ទី៨) ខ្មែរក្រហមបានបង្កសង្គ្រាមជាមួយវៀតណាមនៅតាមព្រំដែនរហូតដល់ថ្ងៃដួលរលំរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

- បញ្ចាំងខ្សែភាពយន្តឯកសារចំនួនពីរ ទី១) ភាពយន្តឯកសារអំពីដំណើរឆ្ពោះទៅសង្គ្រោះជាតិរបស់សម្តេចតេជោ ហ៊ុន សែន និងទី២) ខ្សែភាពយន្តឯកសារអំពីមរតក ២វ ឆ្នូ។







គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម x-16 ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

- បទបង្ហាញ និងពន្យល់អំពីនិយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងកម្រិតបុគ្គល គ្រួសារ ឬសហគមន៍ និងប្រទេសជាតិ ។
- វាស់ស្ទង់ចំណេះដឹងសិស្សក្រោយវេទិកាបញ្ចប់ដោយប្រើប្រាស់កម្រងសំណួរវាស់ស្ទង់មតិ។



គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម x-16 ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ចំណាប់អារម្មណ៍របស់គ្រូ និងសិស្ស

ខ្ញុំឈ្មោះ ឡា មុឡាង មានអាយុ១៨ឆ្នាំ ភេទស្រី គឺជាសិស្សមកពីសាលាអនុវិទ្យាល័យ ហ៊ុនសែនឈូក។ ខ្ញុំមានអារម្មណ៍រំភើប និងសប្បាយចិត្តជាខ្លាំងចំពោះការដែលបានមកចូលរួមនៅថ្ងៃនេះ។ ខ្ញុំបានដឹងពីព្រឹត្តិការណ៍ប្លែកៗដែលខ្ញុំមិនធ្លាប់បានដឹង និងទទួលបានចំណេះដឹងថ្មីៗ ព្រមទាំងបានយល់ដឹងអំពីដំណើរតស៊ូរបស់សម្ដេចតេជោ ហ៊ុន សែន។ ខ្ញុំគិតថាព្រឹត្តិការណ៍សង្គ្រាមដែលបានកើតឡើងនេះ វាពិតជាឃោរឃៅដែលបានសម្លាប់មនុស្សជាច្រើនដែលគ្មានកំហុស។ ខ្ញុំមិនចង់ឲ្យមានសង្គ្រាមកើតឡើងជាលើកទីពីរទេ។ ក្រោយពីបានមកសិក្សា និងបានស្ដាប់លោកគ្រូបកស្រាយរួចមក ខ្ញុំបានយល់ដឹងនិងខ្ញុំចង់ឲ្យក្មេងៗជំនាន់ក្រោយបានរៀនសូត្រអំពីប្រវត្តិសាស្ត្រឲ្យបានច្រើន និងបានដឹងអំពីផលវិបាកនៃសង្គ្រាម និងវិធីទប់ស្កាត់។ បើតាមគំនិតរបស់ខ្ញុំ ចង់មានការផ្សព្វផ្សាយពីវិធានការ និងការទប់ស្កាត់របបប្រល័យពូជសាសន៍ ដើម្បីឲ្យក្មេងៗបានដឹងអំពីបញ្ហារបស់ប្រទេសជាតិពេលមានសង្គ្រាម និងបង្រៀនឲ្យក្មេងជំនាន់ក្រោយស្រឡាញ់សន្តិភាព។ ជាចុងក្រោយ ប្រសិនបើមានឱកាសជាលើកទីពីរ ខ្ញុំចង់ចូលរួមនៅក្នុងកម្មវិធីប្រវត្តិសាស្ត្រនេះទៀត ព្រោះបានផ្តល់បទពិសោធន៍ថ្មីៗជាច្រើនដល់រូបខ្ញុំ។

ខ្ញុំបាទឈ្មោះ លី ស៊ី ភេទប្រុសមានអាយុ១៨ រៀនថ្នាក់ទី១២ គឺជាយុវជនមកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្តុលផ្សារ។ ថ្ងៃនេះខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយក្រៃលែងចំពោះកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់ក្រុមការយុវជនសសយកយុវជនកាកបាទក្រហម មកកាន់មជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្មអិច១៦។ នៅពេលដែលខ្ញុំបានសិក្សា និងបានទស្សនាខ្សែភាពយន្តឯកសារខ្លីៗដែលនិយាយអំពីប្រវត្តិសាស្ត្រ និងថ្នាក់ដឹកនាំរួចមក ធ្វើឲ្យខ្ញុំដឹងពីការលះបង់ និងការតស៊ូរបស់ថ្នាក់ដឹកនាំឆ្ពោះទៅរកសន្តិភាព និងការអភិវឌ្ឍន៍។ ម៉្យាងទៀតបានឲ្យខ្ញុំយល់ដឹងពីព្រឹត្តការណ៍ថ្មីៗជាច្រើន។ ជាចុងក្រោយ ខ្ញុំសូមអរគុណចំពោះបងៗក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មដែលបានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រឲ្យក្មេងៗជំនាន់ក្រោយបានសិក្សា




គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម x-16 ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រៀនសូត្រ និងឈ្វេងយល់អំពីបញ្ហានៃសង្គ្រាម ព្រមទាំងបង្រៀនឲ្យយុវជនស្រឡាញ់សន្តិភាព។ ខ្ញុំសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកោះថ្មបន្តធ្វើកម្មវិធីបែបនេះទៀត ដើម្បីឲ្យយុវជនជំនាន់ក្រោយបានចូលរួម។



គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម x-16 ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទស្សនកិច្ចសិក្សាទៅកាន់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ

**ទី ស៊ីថា**



ផ្នែកខាងក្នុងនៃការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ ខ្ញុំបានចេញដំណើរពីមជ្ឈមណ្ឌលឯកសារកោះថ្មកភ្នំពេញ និងបន្តដំណើរទៅកាន់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ ពេលខ្ញុំមកដល់ ខ្ញុំសង្កេតឃើញមជ្ឈមណ្ឌលឯកសារខេត្តតាកែវមានទីធ្លាធំទូលាយ និងរៀបចំមានរបៀប។ នៅផ្នែកខាងក្នុងការិយាល័យមានទូដាក់ឯកសាររូបភាព និងសៀវភៅជាច្រើនក្បាល។ ខ្ញុំបានជួបជាមួយលោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ និងអ្នកស្ម័គ្រចិត្តខេត្តកែវ រួមទាំងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកចិត្តសាស្ត្របរទេសពីររូបទៀត។

នៅវេលាម៉ោង៤:០០រសៀល មានការរៀបចំកម្មវិធីវាស់ស្ទង់កម្រិតនៃការចងចាំរបស់ប្រជាជនមកពីឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវចំនួន៩ នាក់។ កាស្ស៉ា អឹមីលី គឺជាអ្នកចិត្តសាស្ត្រមកពីអឺរ៉ុប បានសួរទៅកាន់អ៊ំពូមីង និង យុវជនដែលមានអាយុ១៥ឆ្នាំឡើង ទាក់ទងជាមួយការធ្វើតេស្តការចងចាំ និងអារម្មណ៍ប៉ះពាល់ដល់ខួរក្បាល បន្ទាប់ពីគាត់ពាក់ឧបករណ៍សម្រាប់វាស់កម្រិតនៃការចងចាំរួចមក។

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៣ ខ្ញុំ, លោក ផេង ពង្សរ៉ាស៊ី និងអ្នកស្ម័គ្រចិត្តខេត្តតាកែវ រួមជាមួយអ្នកចិត្តសាស្ត្របរទេសពីររូបទៀតបានចុះទៅភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានចម្ងាយ២៤គីឡូម៉ែត្រពីការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ នៅទីនោះ ក្រុមការងារបានជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១២នាក់។



ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (វី ស៊ីថា / មជ្ឈមណ្ឌលឯកសារកម្ពុជា )



ទូសៀវភៅនៅក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (វី ស៊ីថា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាកិច្ចចាប់ផ្ដើមកម្មវិធី លោក ផេង ពង្សរ៉ាស៊ី បានថ្លែងអំណរគុណដល់លោកអ៊ំមេភូមិ និងលោកតាលោកយាយអ៊ំពូមីងដែលមកចូលរួម។ លោក ផេង ពង្សរ៉ាស៊ី បានណែនាំអ្នកចិត្តសាស្ត្រទាំងពីររូបដែលមកធ្វើតេស្តចង់ចាំជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីវាស់ស្ទង់កម្រិតនៃការចងចាំ។ បន្ទាប់មក អ្នកចិត្តសាស្ត្រក៏បានធ្វើតេស្តវាស់ស្ទង់ការចងចាំជូនយាយតាអ៊ំពូមីងគ្រប់ៗគ្នា ហើយកម្មវិធីនេះបានបញ្ចប់នៅពេលព្រលប់។



អ្នកចិត្តសាស្ត្របរទេសកំពុងធ្វើតេស្តវាស់ស្ទង់កម្រិតចងចាំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនិងយុវជន។ (វី ស៊ីថា / មជ្ឈមណ្ឌលឯកសារកម្ពុជា)



វី ស៊ីថា កំពុងសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (វី ស៊ីថា / មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកផេង ពង្សរ៉ាស៊ី និងអ្នកចិត្តសាស្ត្របរទេស កំពុងសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (វី ស៊ីថា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ចំណាប់អារម្មណ៍របស់អ្នកស្ម័គ្រចិត្តកម្ពុជា

## ខេត្តតាកែវ ពេលចុះកម្មសិក្សានៅមជ្ឈមណ្ឌលឯកសារ កោះថ្ម ខេត្តត្បូងឃ្មុំ

***ង៉ាន់ វីន***



*វី ស៊ីថា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មកំពុងធ្វើបទបង្ហាញអំពីផែនទីនិងរូបថត។*
*(ង៉ាន់វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ង៉ាន់ វីន គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តតាកែវ បានចុះកម្មសិក្សាទៅកាន់មជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ រយៈពេល៣ថ្ងៃ ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣។ នៅពេលខ្ញុំធ្វើដំណើរទៅដល់ការិយាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម ខ្ញុំសង្កេតឃើញពីខាងក្រៅការិយាល័យមានទីធ្លាធំទូលាយ បរិយាកាសល្អ ព័ទ្ធជុំវិញដោយដំណាំហូបផ្លែ និងរុក្ខជាតិជាច្រើនប្រភេទទៀត។ ចំណែកខាងក្នុងការិយាល័យមានដាក់តាំងរូបថតចំនួន៥ផ្ទាំង និងទូដាក់ឯកសាររាប់ម៉ឺនទំព័រ។

នៅអំឡុងពេលចុះកម្មសិក្សា វី ស៊ីថា ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ជូនខ្ញុំទៅមើលសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម ដែលស្ថិតនៅចម្ងាយប្រមាណ៥០០ម៉ែត្រ ពីការិយាល័យមជ្ឈ-មណ្ឌលឯកសារកោះថ្ម។ នៅទីនោះមានដាក់តាំងពិព័រណ៍រូបថត ផ្ទាំងគំនូរ ផែនទី និងទូដាក់ឯកសារជាច្រើន ដើម្បីរំឭកខួបលើកទី៤៣ឆ្នាំ នៃទិវាចងចាំដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុលពតកាលពីថ្ងៃទី២០ខែមិថុនាឆ្នាំ២០២២។ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានបង្ហាញខ្ញុំអំពីផែនទីត្រង់ចំណុចទីតាំងកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បញ្ជាការដ្ឋានវរសេនាធំ តំបន់២១។ នៅវេលាម៉ោង៩:០០នាទីយប់ថ្ងៃទី២០ ខែ

មិថុនា ឆ្នាំ១៩៧៧ សម្តេចតេជោ ហ៊ុន សែន រួមជាមួយសមមិត្តបួនរូបទៀតគឺ នុច ថន, ញឹកហួន, ស៊ូ គឹម ស្រ៊ាង ហោ សាញ់ និងវ៉ា ប៉ោអ៊ាន បានភៀសខ្លួនទៅប្រទេសវៀតណាម ដើម្បីស្វែងរកជំនួយមករំដោះប្រទេសជាតិចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ប៉ុន្តែ ដោយសារប្រទេសវៀតណាម និងខ្មែរក្រហមកំពុងមានជម្លោះប្រដាប់អាវុធជាមួយគ្នា ធ្វើឲ្យវៀតណាមពិបាកក្នុងការបែងចែករវាងជនភៀសខ្លួន និងទាហានខ្មែរក្រហម។

នៅក្នុងឱកាសនោះ ខ្ញុំក៏បានសិក្សាស្វែងយល់អំពីទំនៀមទម្លាប់របស់ប្រជាជននៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដែលភាគច្រើនគឺជាជនជាតិភាគតិចស្ទៀង។ អ្នកភូមិបាននិយាយរៀបរាប់អំពីប្រវត្តិរោងអ្នកតាស្រុក ស្ថិតនៅក្រោមដើមស្រឡៅ ក្នុងភូមិក្តុលលើ ដែលបច្ចុប្បន្នដើមជ្រៃបានដុះព័ទ្ធជុំជិតដើមស្រឡៅ។ សព្វថ្ងៃអ្នកភូមិនៅតែមានជំនឿ និងគោរពទៅលើអ្នកតាស្រុកដដែល។ អ្នកភូមិបានរៀបរាប់បន្តថា មុនថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ប្រជាជនតែងតែរៀបចំពិធីមួយ ដើម្បីបណ្តេញឧបទ្រព អពមង្គល និងគ្រោះចង្រៃចេញពីភូមិ។ នៅក្នុងពិធីនេះ ប្រជាជនប្រមូលគ្នីគ្នាកាន់ដំបងគ្រប់ដៃវាយសម្លាប់សត្វណាដែលបានដើរឆ្លងកាត់ផ្លូវ ឬកាត់ផ្ទះ ដូចជាមាន់ទា ជ្រូកគោ ក្របី (សព្វថ្ងៃប្រជាជនវាយសម្លាប់តែមាន់ និង ទា ប៉ុណ្ណោះ) ព្រោះមានជំនឿថា សត្វទាំងនោះជាព្រាយបិសាចឬសត្វចង្រៃ ព្រមទាំងដើរគោះតាមដើមឈើ និងគោះជញ្ជាំងផ្ទះជាដើម។

ក្រៅពីនេះ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បាននាំខ្ញុំទៅទស្សនាតំបន់ប្រវត្តិសាស្ត្រ X-16 កន្លែងដើមទ្រយឹង។ តមក ខ្ញុំទៅមើលវត្តក្តុល ឬហៅថា វត្តហត្ថិវនារាម ស្ថិតនៅភូមិក្តុលផ្សារ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងនឹងរៀបចំកម្មវិធីសុខភាពតាមរយៈការធ្វើសមាធិរបស់ចាស់ទុំនៅថ្ងៃសីល ហើយលើកទឹកចិត្តគាត់ឲ្យចែករំលែកបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហមទៅកាន់ក្មេងជំនាន់ក្រោយ។ ជាចុងក្រោយ ខ្ញុំបានយល់ដឹងអំពីប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ ជាពិសេស ការរស់នៅរបស់ប្រជាជននៅតំបន់កោះថ្ម។



ទូដាក់ឯកសារនៅការិយាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



ពិព័រណ៍រូបថតនៅការិយាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រជាជន មន្ត្រីមូលដ្ឋានឃុំ និងសិស្សានុសិស្ស

## មកទស្សនាពិព័រណ៍រូបថតអចិន្ត្រៃយ៍ និងឈ្វេងយល់ពីកិច្ចការងារ របស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ

ដេង ពង្សរ៉ាស៊ី



ប្រជាជន មន្ត្រីមូលដ្ឋានឃុំ និងសិស្សានុសិស្សមកទស្សនាពិព័រណ៍រូបថតអចិន្ត្រៃយ៍ និងឈ្វេងយល់ពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅខែមករា ឆ្នាំ២០២៣នេះ មានភ្ញៀវប្រុសស្រីចំនួន៥៧ នាក់ បានមកទស្សនាពិព័រណ៍រូបថតអចិន្ត្រៃយ៍ និងឈ្វេងយល់ពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ ភ្ញៀវទាំងនោះរួមមានគ្រូបង្រៀន និងយុវជនវ័យក្មេងដែលជាសិស្សានុសិស្សនៅវិទ្យាល័យ ហ៊ុន សែន កោះអណ្តែត ចំនួន៣៥នាក់ និងប្រជាពលរដ្ឋដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន២២នាក់។

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានបង្ហាញពីផ្ទាំងពិព័រណ៍នីមួយៗដល់ សិស្សានុសិស្ស និងសម្របសម្រួលដល់អ្នករស់រានមានជីវិតក្នុងការដើរទស្សនាពិព័រណ៍រូបថតទាំងអស់។ សម្រាប់យុវជនដែលមានអាយុទើបតែ១៧ ឬ១៨ឆ្នាំ អ្នកទាំងនោះបានបង្ហាញពីការចាប់អារម្មណ៍ខ្លាំងលើផ្ទាំងរូបថតបង្ហាញអំពី«ប៉ុល ពត និងបក្ខពួក» និង«តាម៉ុក»។ យុវជនទាំងអស់ សុទ្ធតែបានដឹងថា តាម៉ុក គឺជាប្រធានភូមិភាគនិរតី ដែលមានកំណើតនៅក្នុងខេត្តតាកែវ។ អ្នកទាំងនោះគិតថា តាម៉ុក គឺជាអ្នកខេត្តតែមួយជាមួយនឹងខ្លួន។ ម្នាក់ៗបានចោមរោមមើលផ្ទាំងពិព័រណ៍«តាម៉ុក» ដោយស្ងៀមស្ងាត់ និងយកចិត្តទុកដាក់។ នៅពីមុខផ្ទាំងពិព័រណ៍ «ប៉ុល ពត និងបក្ខពួក»



ប្រជាជន មន្ត្រីមូលដ្ឋានឃុំ និងសិស្សានុសិស្សមក ទស្សនាពិព័រណ៍រូបថតអចិន្ត្រៃយ៍ និងឈ្វេងយល់ពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







យុវជនមួយចំនួនបានសួរនាំអំពីបណ្តុំរូបថតតូចៗជាច្រើនសន្លឹកដែលមាននៅលើផ្ទាំងពិព័រណ៍ធំនេះ។ អ្នកខ្លះកត់ត្រា អ្នកខ្លះប្រាប់គ្នីគ្នាអំពីរូបថត និងអ្នកខ្លះឈ្ងោកទៅជិតផ្ទាំងពិព័រណ៍ ដើម្បីអានចំណងជើងរូបថត។

ចំណែកឯអ្នកភូមិចំនួន២១នាក់វិញ ហាក់បង្ហាញការចាប់អារម្មណ៍ខ្លាំងតែចំពោះផ្ទាំងពិព័រណ៍ «តាម៉ុក» និងបានជជែកគ្នាពុំពីខ្សែជីវិតរបស់ តាម៉ុក។ ដោយសារអ្នកទាំងនោះ មានស្រុកកំណើតជាមួយ តាម៉ុក និងស្គាល់ តាម៉ុក គ្រប់ៗគ្នាផងនោះ ពួកគាត់បានជជែកគ្នាច្រើនពី តាម៉ុក។ សមាជិកក្រុមប្រឹក្សាឃុំលាយបូរ ស្រុកត្រាំកក់ ឈ្មោះ ជា សុខុនបានចូលមកកាន់បរិវេណមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដើម្បីទស្សនាពិព័រណ៍រូបថត។ គាត់បានចាប់អារម្មណ៍ខ្លាំងពីផ្ទាំងពិព័រណ៍រូបថត «តាម៉ុក» និង ផ្ទាំងពិព័រណ៍ស្ពានជ្រោយចង្វារដែលបាក់ស្រុតចូលក្នុងទន្លេកាលពីឆ្នាំ ១៩៧៤។

សុខុនបានប្រាប់ថា គាត់ធ្លាប់ធ្វើការជាមួយ តាម៉ុក មួយរយៈពេលខ្លីដែរ ប៉ុន្តែមិនស្គាល់ពីប្រវត្តិរបស់ តាម៉ុក ច្បាស់លាស់។ សុខុនបានស្នើសុំឯកសារ ដែលទាក់ទងនឹងប្រវត្តិរបស់ តាម៉ុក។ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានប្រគល់សៀវភៅ



ប្រជាជន មន្ត្រីមូលដ្ឋានឃុំ និងសិស្សានុសិស្សមកទស្សនាពិព័រណ៍រូបថតអចិន្ត្រៃយ៍ និងឈ្វេងយល់ពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ», «បូជាភ្លើង», «ទស្សនាវដ្តីស្វែងរកការពិត» និង ឯកសារមួយចំនួនទៀត ដល់គាត់ដើម្បីអាន និងទុកជាឯកសារ។

មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បើកដំណើរការរៀងរាល់ថ្ងៃចន្ទដល់សុក្រ ព្រឹកពីម៉ោង៧ កន្លះដល់ម៉ោង១២ និងរសៀលពីម៉ោង១កន្លះដល់ម៉ោង៥ ដើម្បីទទួលភ្ញៀវចូលទស្សនា និងស្រាវជ្រាវឯកសារប្រវត្តិសាស្ត្រខ្មែរក្រហម ជាច្រើនដែលមានតម្កល់នៅក្នុងការិយាល័យនេះ។ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ នឹងចាប់ផ្តើមចាក់បញ្ចាំងខ្សែភាពយន្តឯកសារប្រវត្តិសាស្ត្រទាក់ទងនឹងរបបខ្មែរក្រហម ចាប់ពីខែកុម្ភៈ ឆ្នាំ២០២៣ តទៅ។





# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)

**ទូច វណ្ណេត**



នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សានុសិស្សកំពុងសិក្សានៅថ្នាក់ទី១២ ចំនួន៦០នាក់ មកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៤ខែមករាឆ្នាំ២០២៣សិស្សានុសិស្សវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចំនួន៦០នាក់ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ វេទិកាថ្នាក់រៀនចុងសប្តាហ៍នេះរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម គឺដើម្បីជំរុញការយល់ដឹងរបស់សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២ពីប្រវត្តិសាស្ត្រខ្មែរក្រហម។ វេទិកាថ្នាក់រៀនចុងសប្តាហ៍នេះ រួមបញ្ចូលកម្មវិធីសិក្សាបន្ថែមរួមមាន៖ ការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ការទស្សនាពិព័រណ៍ ការជួបសន្ទនាផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ការចុះទៅកាន់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍ និងការចុះទៅកាន់ទីតាំងអតីតសមរភូមិប្រទាញប្រទង់រវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។

## • ការមកដល់របស់សិស្សានុសិស្សវិទ្យាល័យ ឈីន លាន ហាន់ជ័យ

នៅវេលាម៉ោង៨:២០នាទីព្រឹក ទូច វណ្ណេត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួល



នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនចុងសប្ដាហ៍ ស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សានុសិស្សកំពុងសិក្សានៅថ្នាក់ទី១២ ចំនួន៦០នាក់ មកពីវិទ្យាល័យឈឺន លាន ហាន់ជ័យ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្វាគមន៍ការមកដល់របស់យុវសិស្ស និងចុះឈ្មោះអ្នកចូលរួមវេទិកាថ្នាក់រៀនថ្ងៃសៅរ៍នេះ។ បន្ទាប់មកវណ្ណេត បានផ្ដល់បទបង្ហាញយ៉ាងខ្លីអំពីមជ្ឈមណ្ឌលឯកខេត្តកំពង់ចាម និងកិច្ចការងារស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយ ទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម។ វណ្ណេត បន្តប្រាប់សិស្សានុសិស្សអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានសាខានៅតាមបណ្ដាខេត្តមួយចំនួន ក្នុងនោះ ក៏មានមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមដែរ។ តមក គឺជាការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

## • បទបង្ហាញស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

នៅវេលាម៉ោង៩:០០នាទី លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ចាប់ផ្ដើមធ្វើបទបង្ហាញរបស់ខ្លួនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ មុនការបង្រៀនរបស់លោក ផេង ពង្សរ៉ាស៊ី បានឲ្យសិស្សានុសិស្សបំពេញកម្រងសំណួរស្ទាបស្ទង់មតិមុនវេទិកាថ្នាក់រៀន ដើម្បីវាស់ស្ទង់ចំណេះដឹងពីមុនរបស់សិស្ស។ ជាកិច្ចបន្ត លោក ផេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា។ បទបង្ហាញរបស់លោក ផេង ពង្សរ៉ាស៊ី មានរយៈពេលជិត២ម៉ោង។ ចំណុចសំខាន់ក្នុងបទបង្ហាញគឺ៖ ទី១) បរិបទប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ, ទី២) និយមន័យនៃអំពើប្រល័យពូជសាសន៍, ទី៣) ការប្រើប្រាស់ចំណេះដឹងរបស់ខ្លួនដើម្បីចូលរួមទប់ស្កាត់អំពើហិង្សា ឬអំពើប្រល័យពូជសាសន៍នាពេលអនាគត និង ទី៤) ការផ្លាស់ប្ដូរគំនិតពីការប្រព្រឹត្តអំពើហិង្សាទៅជាកសាងសន្តិភាពក្នុងកម្រិតបុគ្គល គ្រួសារ និងសហគមន៍។ នៅឱកាសនោះ សិស្សានុសិស្សបានចោទសួរសំណួរជាច្រើនទៅកាន់លោកគ្រូរ៉ាស៊ី ដើម្បីបកស្រាយ និងស្រាយចម្ងល់របស់ខ្លួន។

នៅចុងបញ្ចប់ លោក ដេង ពង្សរ៉ាស៊ី បានចែកសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» ជាភាសាខ្មែរ បោះពុម្ពលើកទី២ និងទស្សនាវដ្តីស្វែងរកការពិតឲ្យសិស្សានុសិស្សទុកអាន និងសិក្សាបន្ថែមពីប្រវត្តិសាស្ត្រនេះ។ បទបង្ហាញរបស់លោក ដេង ពង្សរ៉ាស៊ី បញ្ចប់នៅវេលាម៉ោង១១:៣០នាទី។

### • ការទស្សនាពិព័រណ៍ និងឯកសារខ្មែរក្រហម

ដោយនៅសល់ពេលវេលា ៣០នាទី មុនពេលសម្រាកអាហារថ្ងៃត្រង់ លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បង្ហាញដល់សិស្សានុសិស្សអំពី ពិព័រណ៍រូបថត បណ្ណាល័យខ្មែរក្រហម និងឯកសារបទសម្ភាសន៍។ លោក ស៊ាង ចិន្តា ដឹកនាំសិស្សានុសិស្សទៅទស្សនា ផ្ទាំងរូបថតទាំងនេះ និងពន្យល់អំពីពិព័រណ៍ដែលត្រូវបានដាក់តាំងបង្ហាញនៅ ខាងមុខបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ផ្ទាំងពិព័រណ៍ទាំងនេះ រួមមាន ប្រវត្តិមេដឹកនាំខ្មែរក្រហម ការជម្លៀសប្រជាជន និងការធ្វើការងារនៅការដ្ឋាន។ បន្ទាប់មកយុវសិស្ស បានចូលមកកាន់សាលពិព័រណ៍រូបថតដែលមានការដាក់



នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សានុសិស្សកំពុងសិក្សានៅថ្នាក់ទី១២ ចំនួន៦០នាក់ មកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តាំងបង្ហាញព្រះឆាយាល័ក្ខណ៍ចំនួន១៨ផ្ទាំង ដែលជាផ្នែកមួយនៃពិព័រណ៍ "ក្តីសុបិនកម្ពុជា" ដែលត្រូវបានដាក់តាំងបង្ហាញដោយ «បណ្ណាល័យសម្តេចម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងព្រះរាជកម្មវិធី "១០០ព្រះវស្សានៃព្រះបិតាឯករាជ្យជាតិ" ដើម្បីឧទ្ទិសថ្វាយព្រះបរមរាជវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ នៅសាលមហោស្រពចតុមុខកន្លងមក។ លោក ស៊ាង ចិន្តា បន្តដឹកនាំសិស្សានុសិស្សចូលទស្សនាបណ្ណាល័យខ្មែរក្រហមដែលមានតម្កល់សៀវភៅទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហមជាច្រើន។ ជាកិច្ចបញ្ចប់ សិស្សានុសិស្សទាំងអស់ត្រូវបាននាំទៅកាន់បន្ទប់តម្កល់ឯកសារខ្មែរក្រហម និងអានឯកសារបទសម្ភាសន៍។ ការទស្សនាពិព័រណ៍ និងឯកសារខ្មែរក្រហម បានបញ្ចប់ត្រឹមវេលាម៉ោង១១:៥០នាទី។

### • ការចុះទៅកាន់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍ និងទីតាំងអតីតសមរភូមិរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម

កម្មវិធីពេលរសៀលសម្រាប់វេទិកាថ្នាក់រៀនចុងសប្តាហ៍នេះគឺការចុះទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ និងទីតាំងអតីតសមរភូមិរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ដែលចាប់ផ្តើមវេលាម៉ោង១:៣០នាទី និងបញ្ចប់នៅវេលាម៉ោង៣:៣០នាទីរសៀល។ យុវសិស្សចុះទៅកាន់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍ដែលស្ថិតនៅវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ នៅពេលទៅដល់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍ សិស្សានុសិស្សទាំងអស់ត្រូវបានបែងចែកជា២ក្រុម ដែលក្រុមនីមួយៗបានជួបសន្ទនាផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ សិស្សានុសិស្សក្រុមទី១ គឺត្រូវជួបជាមួយលោក តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានភូមិចំការសាមសិប។ លោក តុង សុភា បាននិយាយប្រាប់សិស្សានុសិស្សក្រុមទី១អំពីទីតាំងសម្លាប់ប្រជាជននៅក្នុងឃុំគគរក្នុងរបបខ្មែរ

ក្រហម, បទពិសោធន៍ និងការបាត់បង់ឪពុក ដោយសារតែខ្មែរក្រហមមកពីភូមិភាគនិរតីចាប់យកទៅសម្លាប់ និងការសាងសង់ចេតិយរំឭកសម្រាប់សហគមន៍។ ខណៈពេលដែលនិយាយប្រាប់រឿងរ៉ាវទាំងអស់នេះ លោក តុង សុភា នាំសិស្សានុសិស្សក្រុមទី១ដើរឆ្លងកាត់វាលស្រែឆ្ពោះទៅកាន់ចេតិយរំឭក។ ចំណែកឯ យុវសិស្សក្រុមទី២ គឺត្រូវជួបជាមួយអ្នកស្រី បួន ចាន់ថុល អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នកស្រី បួន ចាន់ថុល គឺជាអតីតកងចល័តនារី និងបានបាត់បង់ឪពុក និងបងប្អូនរបស់ខ្លួន ដែលត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់។ អ្នកស្រី បួន ចាន់ថុល ចែករំលែកទៅកាន់យុវសិស្សក្រុមទី២អំពីបទពិសោធន៍ការធ្វើការងារហួសកម្លាំង ការហូបចុកមិនគ្រប់គ្រាន់ និងការបាត់បង់សមាជិកគ្រួសារនៅក្នុងរបបខ្មែរក្រហម។ ជំនួបសន្ទនាផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅចេតិយរំឭកនេះបង្កើតឱកាសដល់សិស្សានុសិស្សឈ្វេងយល់ដោយផ្ទាល់ពីរឿងរ៉ាវកើតឡើងក្នុងមូលដ្ឋានក្នុងរបបខ្មែរក្រហម និងសួរនូវអ្វីដែលខ្លួនចង់ដឹងទៅកាន់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ យុវសិស្សបានចំណាយរយៈពេលជិត២ម៉ោងក្នុងកិច្ចសន្ទនាអន្តរជំនាន់ នៅចេតិយរំឭកសម្រាប់សហគមន៍នេះ។





នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សានុសិស្សកំពុងសិក្សានៅថ្នាក់ទី១២ ចំនួន៦០នាក់ មកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាកិច្ចបន្ទាប់ យុវសិស្សបានបន្តចុះទៅទីតាំងប្រវត្តិសាស្ត្រមួយទៀត គឺវត្តរកាគយ ដែលជាអតីតបន្ទាយទាហាន លន់ នល់ និងទីតាំងសមរភូមិក្តៅរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ លោក ស៊ាង ចិន្តា បានពន្យល់រៀបរាប់ទៅកាន់យុវសិស្សពីប្រវត្តិខ្លះៗអំពីព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងមូលដ្ឋាននេះ។ បន្ទាប់ពីមានរដ្ឋប្រហារ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ស្ថានភាពនៅក្នុងភូមិសាស្ត្រនេះបានផ្លាស់ប្តូរទាំងស្រុង។ អ្នកភូមិជាច្រើនបានចូលរួមបាតុកម្មដង្ហែទៅកាន់ទីរួមខេត្តកំពង់ចាម និងបន្តទៅទីក្រុងភ្នំពេញ។ នៅចុងឆ្នាំ១៩៧០កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ និងសុំស្នាក់នៅក្រោមផ្ទះអ្នកភូមិ។ សមរភូមិប្រយុទ្ធរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើងទាំងផ្លូវគោក និងផ្លូវទឹក។ ទាហាន លន់ នល់ ត្រូវបានបញ្ជូនមកកាន់បន្ទាយទាហាននៅក្នុងវត្តរកាគយ ដើម្បីទប់ទល់ជាមួយកងទ័ពរំដោះខ្មែរក្រហម។ នៅចន្លោះចុងឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ បន្ទាយទាហានលន់នល់នៅវត្តរកាគយត្រូវបានវាយបែក និងរំដោះដោយកងទ័ពរំដោះខ្មែរក្រហម។ វត្តរកាគយត្រូវបានប្រើប្រាស់ទៅជាកន្លែងភស្តុភាររបស់កងទ័ពរំដោះខ្មែរក្រហម។ នៅឆ្នាំ១៩៧៣ ទីរួមខេត្តកំពង់ចាមត្រូវបានព័ទ្ធជុំវិញដោយកងទ័ពរំដោះខ្មែរក្រហម។ ក្នុងស្ថានភាពបែបនេះ ទាហាន លន់ នល់ ប្រើប្រាស់ផ្លូវទឹកដែលជាច្រកចេញចូលសំខាន់ក្នុងការដឹកជញ្ជូនសម្ភារសឹក ស្បៀង និងប្រជាជននៅទីរួមខេត្តកំពង់ចាមចេញទៅកាន់ទីក្រុងភ្នំពេញ តាមរយៈនាវាម៉ារីនទាហាន លន់ នល់។ យ៉ាងណាក៏ដោយ ការ

ដឹកជញ្ជូនតាមផ្លូវទឹកនេះតែងតែទទួលរងការវាយប្រហារដោយកងទ័ពរំដោះខ្មែរក្រហម។

**• ទស្សនយល់ឃើញរបស់យុវសិស្ស បន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍**

សិស្ស ទី លីហួរ រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិត នៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចែករំលែកចំណាប់អារម្មណ៍របស់ខ្លួនថា «ខ្ញុំទទួលបានចំណេះដឹងថ្មីៗពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យតាមរយៈបទបង្ហាញក្នុងវេទិកាថ្នាក់រៀនចុងសប្តាហ៍នេះ។ បន្ថែមលើនេះទៀត ខ្ញុំបានឃើញរូបថតដែលប្រជាជនខ្មែរទទួលទុក្ខលំបាកក្នុងរបបខ្មែរក្រហម និងស្តាប់បទពិសោធន៍ជីវិតរបស់អ៊ំស្រី ចាន់ ថុល ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំពិតជាមានចិត្តអាណិតអាសូរដល់ប្រជាជនខ្មែរជំនាន់មុនដែលបានឆ្លងកាត់សង្គ្រាម ការលំបាកវេទនា និងការបាត់បង់។ ក្នុងនាមជាយុវជនជំនាន់ក្រោយ ខ្ញុំនឹងចូលរួមទប់ស្កាត់កុំឲ្យរបបនេះវិលមកវិញម្តងទៀត។»

សិស្ស ឈឿន ឧត្តម រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិត នៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ បង្ហាញការពេញចិត្តរបស់ខ្លួនចំពោះវេទិកាថ្នាក់រៀនចុងសប្តាហ៍នេះថា «ខ្ញុំពេញចិត្តវេទិកានេះ ពីព្រោះខ្ញុំទទួលបានចំណេះដឹងយ៉ាងច្រើនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម ដែលបានបង្កឲ្យមានការស្លាប់ប្រជាជនខ្មែររាប់លាននាក់ និងបំផ្លិចបំផ្លាញប្រទេសជាតិ។ ចំណេះដឹងថ្មីៗដែលខ្ញុំទទួលបានពីវេទិកានេះ គឺការរស់នៅរបស់ប្រជាជនក្នុងរបបខ្មែរក្រហម សេដ្ឋកិច្ចនិងការនាំចេញ និងនាំចូលផលិតផល និងមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ»។

សិស្ស ទ្រី សុគុណរតនា រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិត នៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ លើកឡើងពីចំណេះដឹងដែលខ្លួនទទួលបានពីវេទិកាថ្នាក់រៀនចុងសប្តាហ៍នេះថា «ខ្ញុំទទួលបានការយល់ដឹងថ្មីៗពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈបទបង្ហាញរបស់លោកគ្រូ។ នាងខ្ញុំឃើញរូបភាពជាច្រើនពីសម័យ ប៉ុល ពត ជាលើកទី១។ ខ្ញុំមានចិត្តអាណិតអាសូរដល់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។





នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សានុសិស្សកំពុងសិក្សានៅថ្នាក់ទី១២ ចំនួន ៦០នាក់ មកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ

*ឌីម សុខគា*



សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កោះអណ្តែត ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» រៀបចំដោយមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសាខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» ដំបូងនៅដើមឆ្នាំ២០២៣។ វេទិកាថ្នាក់រៀននេះមានការចូលរួមពីសិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុនសែនកោះអណ្តែតចំនួន៣៥នាក់ក្រោមការដឹកនាំរបស់លោកគ្រូ-អ្នកគ្រូ ឯកទេសប្រវត្តិវិទ្យាចំនួន២រូប។ វេទិកាថ្នាក់រៀននេះជំរុញលើកទឹកចិត្តដល់យុវជន និងក្មេងៗជំនាន់ក្រោយឲ្យខិតខំប្រឹងប្រែងរៀនសូត្រ និងចងចាំអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា ជាពិសេសរបបខ្មែរក្រហម ដើម្បីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមកើតឡើងម្តងទៀត។

នៅវេលាម៉ោង៨កន្លះព្រឹក ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ សិស្សានុសិស្សបានមកដល់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ និងបានទស្សនាពិព័រណ៌រូបថតដែលស្ថិតនៅខាងមុខ និងខាងក្នុងការិយាល័យ។ សិស្សានុសិស្សទាំងអស់ត្រូវបានណែនាំឲ្យស្គាល់ពីឯកសារខ្មែរក្រហមដែលមាននៅក្នុងទូដែកស្ថិតនៅខាងក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ នៅក្នុងឱកាសនោះ យុវជនមួយចំនួនបានសួរសំណួរទាក់ទងនឹងផ្ទាំងរូបថត និងឯកសារខ្មែរ



ក្រហម។ បន្ទាប់មក យុវជនទាំងអស់ត្រូវឲ្យបំពេញកម្រងសំណួរវាស់ស្ទង់ចំណេះដឹង មុនពេលវេទិកាថ្នាក់រៀនចាប់ផ្តើម។

លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចាប់ផ្តើមធ្វើបទបង្ហាញ បន្ទាប់ពីសិស្សានុសិស្សបានបំពេញកម្រងសំណួរវាស់ស្ទង់ចំណេះដឹងរួច។ ដោយមានសំណូមពរពីគ្រូដឹកនាំសិស្ស លោក ផេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញទាក់ទងនឹងប្រធានបទ «មូលហេតុនៃការកើតឡើងរបបខ្មែរក្រហម»។ បន្ទាប់ពីបញ្ចប់ការធ្វើបទបង្ហាញលើប្រវត្តិសាស្ត្រខ្មែរក្រហម លោក ផេង ពង្សរ៉ាស៊ី បន្តធ្វើបទបង្ហាញអំពីនិយមន័យអំពើប្រល័យពូជសាសន៍ និងវិធីសាស្ត្រជាក់លាក់ក្នុងការទប់ស្កាត់អំពើហិង្សាក្នុងកម្រិតបុគ្គល គ្រួសារ សហគមន៍និងប្រទេសជាតិ។

បន្ទាប់ពីរយៈពេលប្រមាណជា២ម៉ោងនៃការធ្វើបទបង្ហាញ លោក ផេង ពង្សរ៉ាស៊ី តម្រូវឲ្យសិស្សានុសិស្សបំពេញកម្រងសំណួរវាស់ស្ទង់ចំណេះដឹងក្រោយវេទិកា ដើម្បីចង់ដឹងថាតើចំណេះដឹងសិស្សានុសិស្សកើនឡើងប៉ុណ្ណាណ។ បន្ទាប់មក ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ,





សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កោះអណ្តែត ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» រៀបចំដោយមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



*សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កោះអណ្តែត ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» រៀបចំដោយមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

គ្រូដឹកនាំ និងសិស្សានុសិស្សបានថតរូបជុំគ្នា ទុកជាអនុស្សាវរីយ៍។

នៅវេលាម៉ោង២ពេលរសៀល សិស្សានុសិស្សទាំងអស់បានធ្វើដំណើរទៅកាន់អតីតមន្ទីរសន្តិសុខក្នុងរបបខ្មែរក្រហម ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ដើម្បីស្តាប់ការចែករំលែករឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទីនោះ។ លោកតា សេង ហេង សព្វថ្ងៃមានអាយុ៧៥ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានរៀបរាប់ទាក់ទងទៅនឹងទីតាំងមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រាំងតាចាន់ នៅក្នុងរបបខ្មែរក្រហមថា មន្ទីរសន្តិសុខនេះ គឺជាកន្លែងបង្អត់អាហារអ្នកទោស ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់អ្នកទោស។ បន្ទាប់ពីរៀបរាប់រួចហើយ លោកតា សេង ហេង បានបង្ហាញសិស្សានុសិស្សទាំងអស់ពីការបណ្តើរអ្នកទោសចូលមន្ទីរសន្តិសុខ កន្លែងឃុំឃាំង កន្លែងសួរចម្លើយ កន្លែងសម្លាប់ ហើយចុងក្រោយ គាត់បាននាំសិស្សានុសិស្សទៅមើលបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហម។



នៅក្នុងឱកាសនោះ លោក ផេង ពង្សរ៉ាស៊ី រៀបរាប់ប្រាប់សិស្សានុសិស្សបន្ថែមពីការបង្កើតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ហើយមន្ទីរសន្តិសុខក្រាំងតាចាន់ គឺជាមន្ទីរសន្តិសុខថ្នាក់ស្រុកមួយក្នុងចំណោមមន្ទីរសន្តិសុខទាំង១៩៧ ដែលខ្មែរក្រហមបានបង្កើតឡើង។ លោក ផេង ពង្សរ៉ាស៊ី ក៏បានលើកឡើងពីការបង្ក្រងរបាយការណ៍លម្អិតទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ ប្រាប់ដល់ក្រុមយុវជនទាំងអស់ឲ្យបានដឹង មុននឹងសិស្សានុសិស្សដើរមើលទីតាំងផ្សេងទៀតនៅជុំវិញមន្ទីរសន្តិសុខនេះ។













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖ truthchenda.s@dccam.org

សូមអរគុណ!















# ក្រាំ ម៉យ ៖ ខ្ញុំបាត់បង់កូនពីរនាក់នៅក្នុងរបបខ្មែរក្រហម



ក្រាំ ម៉យ អាយុ៨០ឆ្នាំ រស់នៅភូមិសំរោងធំ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (ទី ស្រីផា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ក្រាំ ម៉យ អាយុ៨០ឆ្នាំ រស់នៅភូមិសំរោងធំ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ពេលខ្មែរក្រហមចូលមកដល់ក្នុងភូមិ ខ្ញុំនិងគ្រួសារបានរត់ទៅសង្កាត់ភ្នៀត ស្រុកសេរីសោភ័ណសព្វថ្ងៃ។ បន្ទាប់ពីរស់នៅទីនោះអស់រយៈពេលពីរខែ ខ្ញុំត្រូវខ្មែរក្រហមចាត់ឲ្យចូលជាមួយកម្លាំងកាប់ឈើនៅក្នុងព្រៃ។ ខ្ញុំរស់នៅក្នុងព្រៃកាប់ឈើ និង ធ្វើស្រែចម្ការនៅឆ្ងាយគ្មានពេលឈប់សម្រាកនិងមិនដែលមានឱកាសបានជួបប្រពន្ធកូនម្ដងឡើយ។ នៅថ្ងៃមួយ ខ្ញុំទទួលដំណឹងថាកូនប្រុសច្បងរបស់ខ្ញុំបាត់បង់ជីវិត ខ្ញុំក៏សូមខ្មែរក្រហមមកផ្ទះវិញ។ បន្ទាប់ពីកូនប្រុសច្បងរបស់ខ្ញុំស្លាប់ខ្មែរក្រហមបានផ្លាស់ប្រពន្ធរបស់ខ្ញុំពីកងចល័តដកស្ទូងប្រូតកាត់មកធ្វើជាចុងភៅដាំបាយវិញម្ដងដោយខ្មែរក្រហមលើកឡើងថា ប្រសិនឲ្យប្រពន្ធរបស់ខ្ញុំទៅធ្វើការងារនៅឆ្ងាយពីកូនទៀត កូនស្រីទាំងពីរនឹងស្លាប់អស់ជាមិនខាន។ បន្ទាប់ពីប្រពន្ធរបស់ខ្ញុំផ្លាស់មកធ្វើការងារនៅរោងបាយរយៈពេលប្រហែលពីរសប្ដាហ៍ កូនស្រីរបស់ខ្ញុំម្នាក់ទៀតបានស្លាប់ ដែលធ្វើឲ្យប្រពន្ធរបស់ខ្ញុំកាន់តែមានវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ។ បន្ទាប់ពីកូនប្រុសស្រីទាំងពីរនាក់បាត់បង់ជីវិត ខ្ញុំក៏សូមអង្គការឈប់ចូលព្រៃកាប់ឈើត្រឡប់មកផ្ទះវិញ។

នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមចាត់ខ្ញុំឲ្យទៅប្រូតស្រូវនៅឆ្ងាយពីភូមិ។ ថ្ងៃមួយ ខ្ញុំបានឮខ្មែរក្រហមពិភាក្សាគ្នាថាយកមនុស្សនៅក្នុងតំបន់ដែលខ្ញុំរស់នៅ ទាំងអស់ទៅសម្លាប់ចោល។ ខ្ញុំភ័យញ័រដៃញ័រជើង ហើយក៏ធ្វើពុធជាឈឺសូមមកផ្ទះ ខ្មែរក្រហមក៏យល់ព្រម។ ខ្ញុំមានគ្នាបីនាក់ពេលត្រឡប់មកផ្ទះ នៅតាមផ្លូវធ្វើដំណើរបានជួបនឹងយោធាខ្មែរក្រហម។ យោធាទាំងនោះបានសួរពួកខ្ញុំថាទៅណា? ខ្ញុំក៏ឆ្លើយថាខ្ញុំឈឺសូមទៅផ្ទះ។ ពេលនោះទាហានខ្មែរក្រហមម្នាក់មាឌធំខ្មៅ មុខមាំ រាងខ្ពស់ និយាយមកកាន់ពួកខ្ញុំថា «មិត្តឯងទៅណាទៅ

ឲ្យចំគោលដៅដែលអង្គការប្រាប់ កុំទៅខុសកន្លែងប្រយ័ត្នខ្លួន ព្រោះខ្មាំងមានច្រើនណាស់។

បន្ទាប់ពីខ្ញុំមកដល់ផ្ទះបានមួយខែ ថ្ងៃមួយពេលខ្ញុំកំពុងបោកស្រូវនិងបែនស្រូវ ក៏ឮសូរគ្រាប់កាំភ្លើងផ្ទុះនៅពីខាងកើតភូមិ ហើយក៏មានអ្នកស្រែកថាវៀតណាមចូលមកហើយ។ ពេលនោះ ប្រពន្ធរបស់ខ្ញុំបានដឹកដៃកូនរត់មកជួបខ្ញុំនៅស្រែ។ ខ្ញុំបានដឹកគោមួយនឹមមកពីស្រែ ហើយនាំគ្នាមកផ្ទះប្រមូលសម្ភារមួយចំនួន។ ខ្ញុំរត់ទៅសហករណ៍ស្តុកអាហារយកបានឆ្នាំង ១ អំបិល១ចាន ស្ករ១ដៃ និងចានបាយមួយ។ ពេលនោះ ខ្ញុំបានជួបបងប្រុសម្នាក់ជាប្រជាជនថ្មី។ បងប្រុសម្នាក់នោះគាត់មានរទេះ ចំណែកខ្ញុំមានគោ គាត់ក៏សូមខ្ញុំធ្វើដំណើរមកជាមួយប្រពន្ធនិងកូនស្រីរបស់គាត់ពីរនាក់។ ខ្ញុំធ្វើដំណើរជាមួយគាត់ដល់ភូមិស្វាយ គាត់បានប្រគល់រទេះនោះមកឲ្យខ្ញុំរួចក៏ឡើងជិះឡានជាមួយទាហានវៀតណាមចាកចេញទៅ។ បន្ទាប់ពីខ្ញុំរស់នៅជាមួយបងប្រុសនោះបានមួយរយៈ ទើបគាត់ប្រាប់ថាគាត់ជាអតីតមន្ត្រីជាន់ខ្ពស់នៅខេត្តកំពង់ឆ្នាំងក្នុងសម័យ លន់ នល់ គាត់បានដឹងច្បាស់ពីរបបខ្មែរក្រហម ដោយហេតុនេះហើយទើបគាត់ជម្លៀសគ្រួសារគាត់ពីតំបន់មួយទៅតំបន់មួយ ដើម្បីគេចផុតពីការសម្លាប់របស់អង្គការ។ គាត់បានឲ្យខ្សែករមួយខ្សែដែលប្រពន្ធគាត់លាក់ទុកមកឲ្យខ្ញុំ។ ខ្ញុំរស់នៅស្រុកសេរីសោភ័ណរយៈពេល៨ខែ ក៏មករស់នៅភូមិកំណើតវិញ ប៉ុន្តែមិនទាន់មានសន្តិភាពនៅឡើយ ក្រុមគ្រួសាររបស់ខ្ញុំនិងប្រជាជនផ្សេងទៀតត្រូវរត់គេចខ្លួនបុះឡើងៗ ដោយសារតែក្រុមចោរព្រៃខ្មែរក្រហមតែងលួចវាយប្រហារមកលើភូមិរបស់ប្រជាជន។

**ធី ស្រីផា**



គ្រាំ ម៉យ អាយុ៨០ឆ្នាំ រស់នៅភូមិសំរោងធំ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ កំពុងផ្តល់បទសម្ភាសន៍ដល់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ( ទី ស្រីផា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )

## «ទួលពិឃាដ» (ត)

# ១១. ទំព័រជីវិតទី២លើទឹកដីចាស់ (ត)

## មេឃក្នុងពេលរាត្រី

### *ដើមពោធិ៍សម្បុកអក ទួលសំរោងទង (ត)*

*...ខ្ញុំយកក្រមាមករុំខ្លួនឲ្យបាត់រងា។ ខ្លួនរងាញ័ររណ្ដំថ្គាម ឱ! ព្រះសូរិយាអើយបញ្ចេញកម្ដៅឲ្យខ្លាំងមកអ៊ីដែលខ្ញុំបានជួបផលវិបាកខ្ញុំតែងតែនឹកទៅដល់ព្រលឹងឪពុកម្ដាយខ្ញុំជានិច្ច។*

*ខ្ញុំមិនអាចដើរទៅមុខបានទៀតទេ មានអារម្មណ៍វិលមុខធីងធោងស្ទើរតែប្រកាច់។ ខ្ញុំដេករនៀលលើទំនប់យកក្រមាមកដណ្ដប់។ នំអន្សមនំគមជ្រុះរប៉ាត់រប៉ាយរាយពេញផ្លូវ។ ខ្ញុំលើកដៃបួងសួងដល់ឪពុកអ្នកម្ដាយជួយកូនឲ្យធូរស្បើយនូវជំងឺនេះហើយដើរដល់ផ្ទះ។*

*មិនយូរប៉ុន្មានជំងឺនេះហាក់ដូចជាធូរស្បើយ តែខ្ញុំធ្លាប់ដឹងថាជំងឺនេះវាធ្វើទុក្ខពេលយើងត្រូវកម្ដៅព្រះអាទិត្យខ្លាំង និងអារម្មណ៍គិតច្រើនក្នុងរយៈពេលពីដប់ទៅដប់ប្រាំនាទី ពេលវេលានេះវាខ្ចីមែនតែធ្វើឲ្យយើងពិបាកទ្រាំណាស់។*

*ក្នុងអារម្មណ៍ហាក់ដូចជាធូរស្រាល ខ្ញុំរើសនំអន្សមនិងនំគមដាក់ក្នុងថ្នក់ក្រមាដែលប្រឡាក់ដីស្រមកហើយធ្វើដំណើរបន្តទៅមុខទៀត*



*ទិដ្ឋភាព៖ ខ្ញុំត្រឡប់មកពីភូមិយោគ ជំងឺគ្រុនបានរើមកវិញ ដួលសន្លប់នៅក្រោមដើមពោធិ៍សម្បុកអក។ (ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)*

ចូលព្រៃនាមជាមួយ ទឹកភ្នែកហូរចេញមក។

ឱ! សំណល់វាសនាជីវិត ខ្ញុំសូមអង្វរដល់អ្នក បើខ្ញុំរួចពីអន្ទាក់ហើយ កុំធ្លាក់ក្នុងរណ្តៅបន្តទៅទៀត។ ជើងមេឃវែងឆ្ងាយតែមិនអាចបន្ទាយឲ្យដល់ទុក្ខសោកជីវិតខ្ញុំទេ។ ពាក្យពេចន៍ពីបុព្វបានរេដូចជាត្រីវិស័យចង្អុលបង្ហាញនូវផ្លូវ កម្មជីវិតពិតជាជូរចត់ណាស់។ ការព្រាត់ប្រាស ការនិរាសនៅពាសពេញពិភពកង្វល់ ក្នុងវិញ្ញាណខ្ញុំរកគិតអ្វីពុំយល់ ចង់ស្រែកឲ្យបែកផែនដី។

មិនទាន់ហាស្តីផង សត្វអកក៏ហើរចេញពីដើមពោធិ៍ដែលគេហៅថាដើមពោធិ៍សម្បុកអក មកក្រឡឹងដូចជាចង់ខាបយកព្រលឹងខ្ញុំ ដែលកំពុងតែដើរម្នាក់ឯង។ ខ្ញុំនិយាយទៅកាន់វាថា"ឱសត្វអកអើយ អ្នកព្រាត់ប្រាសកូនមិនខុសពីក្បួនជីវិតខ្ញុំព្រាត់ឪពុកម្តាយដូចគ្នាទេ ដូច្នេះកុំប្រឡំថាខ្ញុំយកជីវិតកូនអ្នកឲ្យសោះ"។ អ្វីដែលយើងគិតស្មានមកដល់ពេលនេះដូចតែគ្នា។

មេសត្វអកហើរមករកខ្ញុំជិតទៅៗទាំងសំឡេងអកៗ ហើយចង់ប្រាស់ខ្ញុំ មិនចង់ឲ្យខ្ញុំធ្វើដំណើរទៅមុខបន្តទៀត។ ខ្ញុំយកដៃរងវាពេលដែលវាបោះពួយមករកខ្ញុំម្តងៗ។ អំណាចដែលវាធ្វើអ្វីខ្ញុំមិនបាន វាក៏ហើរទៅសម្បុកវាវិញ ហើយឈរសម្លឹងពីមែកដើមពោធិ៍មកមើលខ្ញុំដោយដង្ហក់ ពេលនោះខ្ញុំគិតថាប្រហែលជាវាខ្លាចក្រែងខ្ញុំឡើងទៅយកកូនវា។

ឱ! សត្វអកអើយ! អ្នកពិតជាគិតខុសហើយ ខ្ញុំរស់នៅយកតែព្រះអាយុសន្សំសេចក្តីសុខទេ។ ខ្ញុំចាប់ផ្តើមបាត់រវាមែនទែនហើយ ក្នុងខ្លួនចាប់ផ្តើមក្តៅនឹងកម្តៅព្រះអាទិត្យ។

ជីវិតក្តៅនឹងព្រះអាទិត្យមិនស្មើនឹងភ្លើងជីវិតទេ ទោះជាអ្នកខំប្រឹងបញ្ចេញរស្មីកម្តៅយ៉ាងណាក៏ដោយ។ ហ៊ឺ! ខ្ញុំលាសិនហើយ សត្វអកអើយ អ្នកនៅជាមួយកូនឲ្យបានសុខសប្បាយចុះ កុំឲ្យដូចខ្ញុំណា ខ្ញុំមើលទៅសត្វអកទំយាមទ្រនំសម្លឹងមើលមករូបខ្លួនឯងសែនសង្វេគពេកក្រៃ។



រូបភាពបច្ចុប្បន្នឆ្នាំ២០១៩៖ ដើមពោធិ៍សម្បុកអក នៅលើទួលសំរោងទងប្រកឥន្ទ្រី។ (ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)

**ឡុង វង្សសមិទ្ធ**

***(តទៅលេខក្រោយ)***

រូបក្របមុខ៖

កងនារីកំពុងជីកប្រឡាយ និងលើកទំនប់នៅការដ្ឋានការងារក្នុងរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩)។

(ហូវ៉ាន់តាយ និង ឌិញ ហុង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

ប្រជាជនមូលដ្ឋានក្នុងរបបខ្មែរក្រហម។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 277, January 2023 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.